D25008

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសជាមួយ ផាន វណ្ណនី ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិឡាវ
## (កូនរបស់ ឡាំង ហៅ ហម គណស្រុកកោះញែក)
## និង ចាន់ គួយ ភេទប្រុស ជនជាតិឡាវ
## ក្នុងភូមិពាមជីមៀត ឃុំពាមជីមៀត (ឃុំណងឃីលីក) ស្រុកកោះញែក ខេត្តមណ្ឌលគិរី
## ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៥
## សម្ភាសដោយៈ អៀ រតនា និង សឹម សុរិយ៉ា

កាសែតទីមួយៈ

ផ្នែក **A:**

រតនាៈ ពូឈ្មោះអីដែរពូ?

នីៈ ឈ្មោះ ផាន វណ្ណនី ។

រតនាៈ សព្វថ្ងៃពូអាយុប៉ុន្មានហើយ?

នីៈ សព្វថ្ងៃ ខ្ញុំអាយុ៣៧ឆ្នាំ ។

រតនាៈ ពូមានស្រុកកំណើតនៅឯណាដែរពូ?

នីៈ នៅជីមៀត ។

រតនាៈ ឃុំ?

នីៈ ឃុំជីមៀត បច្ចុប្បន្នគេហៅឃុំណងឃីលីក ។

រតនាៈ កាលពេលដែលពូកើត គេដាក់ភូមិពាមជីមៀតអ្វេស?

នីៈ បាទ! ផ្លាស់ប្តូរសម័យក្រោយហ្នឹង ផ្លាស់ប្តូរតើ ។

រតនាៈ បានន័យថាឃុំណងឃីលីកហ្នឹងទើបតែផ្លាស់ប្តូរ សម័យ?

នីៈ ផ្លាស់ប្តូរសម័យរដ្ឋកម្ពុជា ។

រតនាៈ ចុះឪពុកពូឈ្មោះអីគេដែរទៅ?

នីៈ ឪពុកខ្ញុំឈ្មោះ ឡាំង សម័យបដិវត្តន៍គេហៅ ឡាំង ។

រតនាៈ ចុះឈ្មោះដើម ។

នីៈ ឈ្មោះដើមឈ្មោះ ខេន ។

រតនាៈ ស្អី ខេន ពូ?

នីៈ ខ្ញុំអត់ចាំទេ ។

រតនា: ចុះឥឡូវគាត់ទៅណាហើយពូ?

នី: គាត់ស្លាប់ហើយ ។

រតនា: ចុះម្តាយពូ?

នី: ម្តាយក៏ស្លាប់ដែរ ។

រតនា: គាត់ឈ្មោះអីដែរ?

នី: ឈ្មោះ ដាន **សៀប ។**

រតនា: គាត់ស្លាប់អាយុប៉ុន្មាន?

នី: អត់ចាំទេ ។

រតនា: ឪពុកម្តាយពូជាលាវសុទ្ធទាំងអស់?

នី: ម្តាយជាលាវសុទ្ធ ឪពុកលាវកាត់ចារាយ ។

រតនា: ចុះពូមានបងប្អូនទាំងអស់ប៉ុន្មាននាក់ពូ?

នី: ៧នាក់ ។

រតនា: ស្រីប៉ុន្មាន ប្រុសប៉ុន្មានដែរពូ?

នី: ស្រីបី ប្រុសបួន ។

រតនា: ចុះឥឡូវនៅរស់ប៉ុន្មាន បាត់ខ្លួនប៉ុន្មាន ស្លាប់ប៉ុន្មានដែរពូ?

នី: នៅរស់ទាំងអស់ ។

រតនា: ចុះពូត្រូវជាកូនទីប៉ុន្មាន?

នី: ខ្ញុំត្រូវជាកូនទី៥ ។

រតនា: បងប្អូនពូរស់នៅក្នុងភូមិហ្នឹងជាមួយគ្នាទាំងអស់?

នី: អត់ទេ នៅស្រុកម៉ាឡៃ ។

រតនា: អីចឹងនៅក្នុងភូមិហ្នឹង មានតែពូមួយទេ?

នី: បាទ! នៅស្រុកម៉ាឡៃ៦នាក់ នៅប៉ៃលិនម្នាក់ ។

រតនា: សព្វថ្ងៃពូមានមុខរបរធ្វើអីដែរពូ?

នី: ធ្វើនគរបាលប៉ុស្តិ៍ ។

រតនា: នៅភូមិហ្នឹងដែរ?

នី: បាទ!

រតនា: ចុះប្រពន្ធពូឈ្មោះអីដែរ?

នី: ប្រពន្ធខ្ញុំឈ្មោះ ខន ។

រតនា: អី ខន ពូ?

នី: **លោក** ខន ។

រតនា: គាត់អាយុប៉ុន្មានហើយពូឥឡូវ?

នី: អាយុ២១ ។

រតនា: គាត់ជាជនជាតិអីដែរ?

នី: ជនជាតិពួកគាត់ចារាយ ។

រតនា: គាត់ធ្វើអីគេពូរាល់ថ្ងៃ?

នី: ប្រពន្ធធ្វើស្រែ ។

រតនា: ចុះពូមានកូនប៉ុន្មាននាក់ដែរ?

នី: កូនមួយ ។

រតនា: ប្រុសឬស្រីពូ?

នី: ប្រុស ។

រតនា: ពូ ខ្ញុំចង់ឲ្យពូរៀបរាប់ពីប្រវត្តិរបស់ឪពុកពូ ថាគាត់បានចូលធ្វើការងាររតាំងពីពេលណា ហើយគាត់បានធ្វើអ្វីខ្លះ តាមដែលពូបានដឹងណា៎?

នី: កាលដែលខ្ញុំចាំ ខ្ញុំនិយាយត្រឹមឆ្នាំ១៩៧៣ យើងនៅអ៨ ។ ខ្ញុំនៅចាំណា៎ ខ្ញុំដឹងក្តី ។ ខ្ញុំដឹងក្តីមកគាត់បានធ្វើគណតំបន់ហើយ ។

រតនា: គណតំបន់១០៥?

នី: បាទ! ១០៥ ។

រតនា: អីចឹងកាលហ្នឹងកន្លែងគាត់ធ្វើការនៅឯណាពូ?

នី: គាត់ធ្វើការនៅអ៨ក្រោម ស្រុកកោះញែក ។

រតនា: កាលហ្នឹងគាត់ទទួលការងាររគណតំបន់ តើគាត់ធ្វើអ្វីខ្លះទៅពូ?

នី: ខ្ញុំអត់ចាំដែរ ខ្ញុំនៅក្មេង ។

រតនា: កាលហ្នឹងពូរស់នៅជាមួយគាត់ដែរ?

នី: បាទ! ខ្ញុំរស់នៅជាមួយគាត់ទាំងម្តាយទាំងឪពុក ។

រតនា: ចុះការងាររបស់គាត់ ពូឃើញគាត់ធ្វើការជាមួយអ្នកណាៗដែរ?

នី: ជំនាន់ហ្នឹងគាត់ធ្វើការច្រើនជាមួយអ្នកកម្មាភិបាលនៅតំបន់ហ្នឹងទេ ។

រតនា: ចុះពូវិញ កាលហ្នឹងពូធ្វើអីដែរ?

នី: ខ្ញុំនៅកុមារ ។

រតនា: អីចឹងពេលពូដឹងក្តីឡើង ពូនៅជាមួយឪពុករបស់ពូនៅគណតំបន់១០៥ហ្នឹង?

នី: បាទ!

រតនា៖ អ៊ីចឹងសូមពូរៀបរាប់មើលថា តើតាំងពីក្មេងមក ពូបានរៀនសូត្រអ្វីខ្លះ រហូតបានចូលធ្វើការ ហើយទៅធ្វើការនៅកន្លែងណា ជាមួយអ្នកណា ហើយមានតួនាទីអ្វីខ្លះរហូតមក?

នី៖ កាលពីឆ្នាំ១៩៧៣, ៧៤ហ្នឹង នៅក្នុងបន្ទុកឪពុកម្ដាយ នៅអ៤ក្រោមហ្នឹង ដល់ពេលមកទល់នឹងឆ្នាំ១៩៧៧ ម្ដាយខ្ញុំស្លាប់ដោយសារភ្លើងឆេះផ្ទះ ហើយឪពុកក៏បញ្ជូនខ្ញុំទៅនៅភ្នំពេញ ឲ្យទៅនៅមន្ទីរ៨៧០ ទៅនៅរៀន។

រតនា៖ ចុះបងប្អូនពូផ្សេងៗទៀត?

នី៖ ផ្សេងៗទៀត គេនៅតាមក្រសួងផ្សេងៗ បែកគ្នាអស់។ បងប្រុសនៅជាមួយឪពុក។

រតនា៖ ឈ្មោះអី?

នី៖ ឈ្មោះ ដាន វ៉ាន។

រតនា៖ កាលហ្នុងគាត់ធ្វើការអីដែរ នៅជាមួឪពុកហ្នឹង?

នី៖ គាត់នៅធ្វើជាកងការពារ នៅបើកឡាន។

រតនា៖ បើកឡានឲ្យឪពុកពូផ្ទាល់តែម្ដង?

នី៖ បាទ!

រតនា៖ បន្ទាប់មកទៀត អ្នកណាទៀត?

នី៖ បងប្រុសម៉ិញហ្នឹង បងទីបីណា។ បងស្រីមួយទៀតណា៎ គាត់មកពីចិនណា៎ តែកាលហ្នុងខ្ញុំអត់ដឹងទេ គាត់មកពីចិនហ្នឹង គាត់មកនៅជាមួយម្ដាយខ្ញុំដែរ គាត់ទទួលខាងសមាគមនារីអ្ហេស។

រតនា៖ អ៎! គាត់បានទៅរៀននៅចិន?

នី៖ ទៅរៀននៅចិន។

រតនា៖ ទៅរៀនតាំងពីពេលណា ហើយអ្នកណាអ្នកបញ្ជូនគាត់ទៅ?

នី៖ ខ្ញុំអត់ចាំបានដែរ។

តួយ៖ តាំងពី៦៨។

រតនា៖ គាត់ឈ្មោះអីដែរពូ?

នី៖ គាត់ឈ្មោះ ដាន ហាន។

រតនា៖ កាលហ្នុងគាត់ទៅរៀនផ្នែកអីដែរពូ?

នី៖ គាត់ទៅរៀនខាងពេទ្យ។

តួយ៖ កិច្ចការនារី។

នី៖ ពេទ្យផង កិច្ចការនារីផង។

រតនា៖ បន្ទាប់មកទៀតពូ?

នី៖ បន្ទាប់មកទៀត គឺបងស្រីឈ្មោះ ដាន ធិ ឈ្មោះបដិវត្តន៍ណា៎ ឈ្មោះពីដើមខ្ញុំអត់ដឹងទេ។

រតនាៈ ដែលថាឥឡូវគាត់រស់នៅម៉ាឡៃហ្នឹងអ្ហេស?

នីៈ នឹងហើយ ។ គាត់នៅសិល្បៈ៣០៤ សិល្បៈតាពួនណ៎ះ នៅកំពង់ចាមណ៎ះ ។

រតនាៈ ចុះបន្ទាប់មកទៀត? បានបីនាក់ហើយ នៅសល់បីនាក់ទៀត ។

នីៈ បីនាក់ទៀត ឈ្មោះ ផាន ឡា ។

រតនាៈ ទាំងអស់ហ្នឹងសុទ្ធតែឈ្មោះបដិវត្តន៍អ្ហេសពូ?

នីៈ ផាន ឡា ហ្នឹង ឆ្នាំចិតប៉ុន្មានទេ គាត់ទៅរៀនពេទ្យនៅភ្នំពេញ ។

រតនាៈ ការផ្លាស់ទាំងអស់ហ្នឹង សុទ្ធតែធ្វើក្រោយបែកភ្នំពេញហើយមែនទេ?

នីៈ អត់ទេ ទៅមុន ។ បងស្រីខ្ញុំបែកពីខ្ញុំទៅមុន ប៉ុន្តែទៅជួបគ្នានៅភ្នំពេញ ។ គាត់ទៅរៀនពេទ្យកុមារ នៅភ្នំពេញ ។

រតនាៈ ពូដឹងថាគាត់នៅពេទ្យណាទេ?

នីៈ ពេទ្យបឹងត្របែកតែម្តង ព្រោះនៅបឹងត្របែកហ្នឹងវាមានសាលារៀនកុមារផង ពេទ្យកុមារផង ។

រតនាៈ ចា៎ះ! ហើយនៅម្នាក់ទៀត?

នីៈ បន្ទាប់មកខ្ញុំ ផាន វណ្ណនី ។ ឆ្នាំ៧៥, ៧៦ បញ្ជូនទៅនៅភ្នំពេញ ។

រតនាៈ កាលហ្នឹងពូអាយុប៉ុន្មានហើយ?

នីៈ អាយុ៧, ៨ឆ្នាំ ។

រតនាៈ អ៊ីចឹងក្រោយបែកភ្នំពេញហើយ បានពូទៅ?

នីៈ បាទ! បែកភ្នំពេញហើយ ។

រតនាៈ ពូទៅរៀនអីគេនៅភ្នំពេញ?

នីៈ ខ្ញុំទៅរៀនភាសាអង់គ្លេស ។

រតនាៈ ឥឡូវនិយាយបានទេ?

សុរិយ៉ាៈ មើលបាន ហើយស្តាប់បានខ្លះ ព្រោះភ្លេចអស់ហើយ ។

រតនាៈ ពូទៅរៀននៅកន្លែងណាដែរពូ?

នីៈ មុនដំបូងទៅរៀននៅបឹងត្របែក នៅមន្ទីរ៨៧០ដំបូង បន្ទាប់មក តាប៉ាំង គាត់បញ្ជូនខ្ញុំទៅរៀននៅបឹងត្របែក ដល់ពេលគេរើពីបឹងត្របែកមក គេមកនៅផ្ទះកោងណ៎ះ កន្លែងមន្ទីរមន្ត្រីឥឡូវនេះណ៎ះ ។

រតនាៈ ទីស្តីការគណរដ្ឋមន្ត្រី ។

នីៈ នឹងហើយ នឹងហើយមកនៅហ្នឹង កន្លែងក្រសួងការបរទេសកាលហ្នុងនោះ ។

រតនាៈ មន្ទីរ៨៧០ហ្នឹង កន្លែងអីគេពូ?

នីៈ មុនដំបូងមន្ទីរ៨៧០ កន្លែងតា ប៉ុល ពត ណ៎ះ ។

សុរិយ៉ាៈ មន្ទីរ៨៧០ហ្នឹង ទន្លេបាសាក់ ។

នីៈ បាទ! ទន្លេបាសាក់ហ្នឹង ។

រតនាៈ ទៅដល់ពូរៀនអង់គ្លេសនៅហ្នឹង?

នីៈ អត់បានរៀនទេ នៅជាកុមារធម្មតាទេអាហ្នឹង នៅជាមួយគាត់ណាំ ។

រតនាៈ នៅជាមួយអ្នកណាគេពូ?

នីៈ នៅជាមួយអ៊ំ ប៉ុល ពត ហ្នឹង ។

រតនាៈ កាលហ្នុងពូធ្វើការងារអីគេ ពេលនៅជាមួយ ប៉ុល ពត?

នីៈ អត់មានធ្វើការអីទេ កុមារនៅជាមួយតែម្តង ។

រតនាៈ កាលហ្នុង គាត់មាននាទីអីគេ កាលពូនៅជាមួយគាត់ហ្នឹង?

នីៈ គាត់ជាលេខាបក្ស ។

សុរិយ៉ាៈ អ៊ីចឹងកាលហ្នុង បងគេហៅឈ្មោះថា ភ៉ាន់ៗ ទទេទេ?

នីៈ បាទ! ហៅ ភ៉ាន់ ។

សុរិយ៉ាៈ បងមានដែលសរសេរសៀវភៅកំណត់ហេតុប្រចាំថ្ងៃទុកទេ?

នីៈ អត់ដែលទុកទេ ។

សុរិយ៉ាៈ មានអ្នកសរសេរកំណត់ហេតុរបស់ អៀង សារី មួយឈ្មោះ ភ៉ាន់ ដែរ មានស្គាល់ទេ មុំនឹង អ្នកធ្វើកំណត់ហេតុ នៅក្បែរ អៀង សារី អីណាំ ឈ្មោះ ភ៉ាន់ ដែរ នៅក្រសួងការបរទេស?

នីៈ ដូចអត់ស្គាល់ ។

រតនាៈ អត់ដែលឮទេ?

នីៈ បាទ! អត់ស្គាល់ ។

រតនាៈ កាលហ្នុង គេអត់មានឲ្យពូធ្វើការអីទេ?

នីៈ អត់ទេ ។

រតនាៈ នៅជាមួយគាត់ហ្នឹង?

នីៈ បាទ! អត់មានធ្វើការអីទេ ដូចថានៅជាកុមារណាំកាលហ្នុង ។

រតនាៈ ហើយក្រៅពីពូ តើមានក្មេងៗផ្សេងៗទៀតនៅដូចជាពូអ៊ីចឹងដែរទេ?

នីៈ មាន មានដូចគ្នា មានប្រមាណជា៤, ៥នាក់ ។

រតនាៈ អ្នកណាខ្លះទៅ ហើយជាកូនរបស់អ្នកណា?

នីៈ ខ្ញុំអត់ស្គាល់ឈ្មោះទេ ភ្លេចអស់ហើយ ព្រោះនៅដោយឡែកៗពីគេ មិនមែននៅជាមួយគ្នាទេ កាលហ្នុង ។

រតនាៈ ម៉េចបានជាគេយកពូទៅនៅជាមួយគាត់?

នីៈ ការទំនាក់ទំនងប្រហែលជាឪពុកខ្ញុំជាមួយនឹងគាត់ហ្នឹងមានការទំនាក់ទំនងគ្នាពីមុនមកណា៎ តាមរយៈគាត់ហ្នឹង ដល់អ៊ីចឹង កាលពីសម័យហ្នុងគេយកកូនកម្មាភិបាលទៅនៅក្បែរថ្នាក់លើដើម្បីបណ្តុះបណ្តាលអ៊ីចឹងណា៎ ។

រតនាៈ ពូដែលឃើញឪពុករបស់ពូទៅជួបគាត់ទេ?

នីៈ ឃើញតើ គាត់ខស្សារាហ៍ទៅជួបដែរហ្នឹង ។

រតនាៈ ជួបនៅផ្ទះដែរពូនៅហ្នឹងអ្ហែស?

នីៈ បាទ!

រតនាៈ ពូស្គាល់ឈ្មោះអង្គរក្សឬក៏និរសាដែលធ្វើការជាមួយ ប៉ុល ពត នៅជាមួយ ប៉ុល ពត ហ្នឹង ពូមានស្គាល់ទេ?

នីៈ ស្គាល់ ស្គាល់ពេទ្យ ។

រតនាៈ អ្នកណាខ្លះពូ?

នីៈ ពេទ្យសឿន បងសុទ្ធ ស្គាល់ច្បាស់ជាងគេណា៎ ដែលនៅចាំ ឥឡូវខ្ញុំចាំមិនអស់ មនុស្សវាច្រើនពេកណា៎ ។ តាំងពីត្រូវរបួសមក ចងចាំអត់បានតែម្តង ។

រតនាៈ ពូ ពេលដែលពូរស់នៅជាមួយគាត់រាល់ថ្ងៃអ៊ីចឹង តើពូឃើញសកម្មភាពគាត់ជាមនុស្សយ៉ាងម៉េចដែរ?

នីៈ កាលដែលខ្ញុំនៅតូចនៅជាមួយគាត់ គ្រាន់តែដឹងថា ក្រៅពីការងារនៅផ្ទះ ឬមួយក៏ដើរលេងតាមសួនច្បារជុំវិញផ្ទះហ្នឹង ។ ការប្រជុំការអីខ្ញុំអត់ដឹងទេណា៎ តែឃើញអ្នកធំអ្នកតូចគេមកអ៊ីចឹងរាក់ទាក់គ្នា ហូបបាយហូបអីខ្ញុំដឹង ជួបជុំគ្នាហូបបាយសើចក្អាកក្អាយធម្មតា តែនៅពេលគាត់នៅធម្មតា គាត់ចូលចិត្តក្មេង ។ តែកាលណាគាត់ដើរលេងល្ងាចៗអ៊ីចឹង គាត់ចូលចិត្តយកខ្ញុំហ្នឹងដើរតាមពីក្រោយគាត់អ៊ីចឹង ។ គាត់ដើរឃើញកៅស៊ូ រើសកៅស៊ូ ឃើញដែកគោលរើសដែកគោល គាត់ថា ឲ្យចេះសន្សំ គាត់ថាអ៊ីចឹងណា៎ របស់នេះប្រើការកើត ។ ខ្ញុំធ្លាប់ដឹងតែប៉ុណ្ណឹងទេ កាលដែលខ្ញុំធ្លាប់នៅជាមួយគាត់កាលពីតូចណា៎ ។ របស់នេះយើងយកទៅទុកចងនេះបាន ហើយដែកគោលនេះយើងយកទៅសន្សំទុក កាលណាយើងរកថ្មីមិនបាន យើងប្រើអាចាស់ហ្នឹងទៅ ។ ចង់និយាយថាគាត់បង្រៀនយើងឲ្យចេះសន្សំសំចៃណា៎ មានតែប៉ុណ្ណឹងទេគាត់នោះ ។

រតនាៈ ហើយជាមួយអ្នកនៅជាមួយគាត់អី តើគាត់ដែលស្តីឲ្យ ដែលវាយ ឬក៏ពេលមានធ្វើអីខុស ពូដែលឃើញគាត់ដាក់ទណ្ឌកម្មទេ?

នីៈ អត់ទេ គាត់ហ្នឹងមិនដែលទេ អាហ្នឹងកាលខ្ញុំរស់នៅជាមួយគាត់ ខ្ញុំឃើញអ៊ីចឹង អត់ដែលស្តីបន្ទោសអីទេ ។

រតនាៈ ពូគិតថាគាត់ស្លូតឬកាច?

នី៖ តាមចរិតរបស់គាត់ ប្រហែលស្លូតទេ ព្រោះខ្ញុំមិនដែលឃើញធ្វើអីកាចលើសពីហ្នឹងណា៎ ធ្វើខុសធ្វើអី គ្រាន់តែហៅមកប្រាប់ ណែនាំអី ។ អារឿងផ្សេងៗទៀត ខ្ញុំអត់ដឹងទេ ធ្លាប់នៅមួយរយៈ ខ្ញុំឃើញអីចឹង ។

រតនា៖ កាលហ្នឹងគាត់នៅកន្លែងហ្នឹង តែកន្លែងដែលគាត់ធ្វើការមិនមែនកន្លែងហ្នឹងទេពូ?

នី៖ មិនមែនទេ ។

រតនា៖ គាត់ទៅធ្វើការនៅឯណា?

នី៖ អត់ដឹងទេ កន្លែងធ្វើការ ខ្ញុំអត់ដឹងទេ ។

រតនា៖ ពូអត់ដែលទៅតាមជាមួយគាត់ទេ?

នី៖ អត់ដែលទេ ។

រតនា៖ គាត់អត់ដែលយកពូទៅក្រៅជាមួយទេ?

នី៖ អត់ដែលទេ អត់ដែលយកទៅជាមួយទេ ។ គ្រាន់តែថាគាត់នាំលេង ឬមួយសម្រាកកំដរគាត់អីអីចឹងណា៎ គាត់ចូលចិត្តក្មេងណាស់ ហើយគាត់អត់ប្រពន្ធផងនោះ ប្រពន្ធគាត់អត់នៅជាមួយគាត់ ។

រតនា៖ ប្រពន្ធគាត់ទៅណាពូ?

នី៖ ប្រពន្ធគាត់នៅមន្ទីរផ្សេង កន្លែងផ្សេងគ្នា ប្រពន្ធមុននោះណា៎ ។

រតនា៖ ឈ្មោះអីគេដែរពូ?

នី៖ គេហៅធម្មតា គេហៅ យាយយឹម ។

រតនា៖ ចុះឈ្មោះពេញពូ?

នី៖ ឈ្មោះ ពណ្ណារី ។

រតនា៖ ពូថាមានប្រពន្ធក្រោយទៀត?

នី៖ ប្រពន្ធក្រោយ យកប្ដីក្រោយទៀត ទេព កាណាល់ នោះ ។

រតនា៖ ប្រពន្ធក្រោយហ្នឹងឈ្មោះអីពូ?

នី៖ ប្រពន្ធក្រោយខ្ញុំចាំបានឈ្មោះ មេន តែអត់ដឹងត្រកូលទេ ។ ឥឡូវគាត់ដាក់ម៉ាស៊ីនស្រូវនៅស្រុកម៉ាឡៃ ។ កូនស្រីរបស់គាត់មួយនៅជាមួយហ្នឹង ។

រតនា៖ កូនគាត់ឈ្មោះអីគេពូ?

នី៖ អត់ស្គាល់ ព្រោះខ្ញុំបែកតាំងពីគាត់អត់ទាន់មានកូន មិនដែលឃើញនេះផង ទើបឃើញពេលគាត់ស្លាប់ហើយ បានឃើញប្រពន្ធគាត់មកនៅហ្នឹង ។

រតនា៖ តែប្រពន្ធក្រោយហ្នឹង គាត់ទើបតែ?

នីៈ ទើបតែយកប៉ុន្មានឆ្នាំនឹងគេ មុនបែកអន្ទង់វៃងណាំ មុននឹងប្រហែលជា១០ឆ្នាំ ខ្ទង់ឆ្នាំ៨៩អីហ្នឹង តាមមើល ។

រតនាៈ ចុះពូក្នុងអំឡុងពេលដែលពូនៅជាមួយ ប៉ុល ពត ហ្នឹង ពូថាដែលឃើញមានអ្នកធ្លាប់ចេញចូលផ្ទះគាត់ តើពូអាចស្គាល់ អាចចាំបានទេ ថាជាអ្នកណាខ្លះ?

នីៈ ជំនាន់ដែល តាប៉ង់ មិនទាន់ស្លាប់ហ្នឹងមានតែ តាប៉ង់ នឹងហើយ ជំនិតរបស់គាត់ហ្នឹង ។

រតនាៈ តាប៉ង់ គាត់ធ្វើអីដែរកាលហ្នឹង?

នីៈ តាប៉ង់ ជាប្រធានមន្ទីរ ។

រតនាៈ មន្ទីរ៨៧០ហ្នឹងអ្ហេស?

នីៈ បាទ!

រតនាៈ គាត់ចេញចូលធ្វើអ្វីខ្លះជាមួយ ប៉ុល ពត ហ្នឹង?

នីៈ អត់ដឹងដែរ អាហ្នឹងការងាររបស់គាត់ ព្រោះខ្ញុំនៅក្មេង ឃើញតែគាត់ទៅមកៗ ។

រតនាៈ កាលហ្នុង ប៉ុល ពត គាត់ជិះឡានអីគេទៅធ្វើការពូ?

នីៈ សូកាឡៀ ។

រតនាៈ ឡានយ៉ាងម៉េចទៅពូ?

នីៈ ឡានកង់បួនយើងហ្នឹង ពីដើមគេហៅសូកាឡៀៗ ។

រតនាៈ ហើយទៅអីចឹង តើមានអង្គរក្សមានអីទៅច្រើនទេពូ?

នីៈ មាន ។ ប្រហែលជាបួន ប្រាំនាក់ ព្រោះពួកហ្នឹងអត់សូវប្រើអង្គរក្សច្រើនប៉ុន្មានទេ អស់ហើយ ៦នាក់អី ជិះក្នុងឡានហ្នឹង ។

រតនាៈ គាត់មិនដែលទៅណាម្នាក់ឯងទេ?

នីៈ គាត់មិនដែលទៅម្នាក់ឯងទេ មានអង្គរក្សទៅតាមគាត់ ។

រតនាៈ ចុះពូកាលហ្នុងគាត់មានកូនទេ ពេលដែលពូនៅជាមួយគាត់ហ្នឹង?

នីៈ អត់មាន ។

រតនាៈ អីចឹងបានន័យថា គាត់យកប្រពន្ធមុនហ្នឹងអត់ទាន់មានកូនទេ?

នីៈ អត់មានកូនមួយទេ ។

រតនាៈ ចុះពូ កាលហ្នុងហេតុអីបានជាគាត់និងប្រពន្ធរបស់គាត់នៅបែកគ្នា?

នីៈ កាលហ្នុងខ្ញុំអត់យល់ដែរ ។ ប្រពន្ធគាត់ក៏ចាស់ដែរហើយណាំ តែឥឡូវគេថាស្លាប់ហើយ ។

រតនាៈ តែមិនដែលឃើញប្រពន្ធគាត់មកផ្ទះដែលគាត់នៅហ្នឹងទេ?

នីៈ អត់ដែលមកទេ ។

រតនាៈ ចុះគាត់មានដែលទៅរកប្រពន្ធគាត់ដែរឬអត់?

នីៈ គាត់ក៏មិនសូវទៅ តែកូនក្មួយគាត់ទេដែលនៅជាមួយ ។ កាលហ្នឹងប្រពន្ធរបស់គាត់នៅចំការមន ណាំ ជិតនាទ់ហ្នឹង ។

រតនាៈ ហើយជិតនាទ់ហ្នឹងប្រពន្ធរបស់គាត់ធ្វើការងាររអីគេពូ?

នីៈ ប្រពន្ធរបស់គាត់អត់មានតួនាទីធ្វើអីផង ។

រតនាៈ អ៊ីចឹងនៅតែផ្ទះ?

នីៈ នឹងហើយ នៅតែផ្ទះ នៅជាមួយប្អូនស្រីគាត់ ។

រតនាៈ ចុះពូ កាលដែលពូរស់នៅជាមួយគាត់ តើការហូបចុកអី តើពូហូបជាមួយគាត់ ឬមួយក៏ហូបផ្សេងគ្នា?

នីៈ ហូបជាមួយតាហ្នឹងអ្ហេស?

រតនាៈ ចាំ!

នីៈ ជួនហូបជាមួយ ជួបហូបនៅផ្ទះបាយ កន្លែងដាំស្ល ។

រតនាៈ អ៊ីចឹងពេលដែលគាត់ហូបបាយ តើហូបរួមគ្នាច្រើនឬក៏ហូបតែម្នាក់ឯង ឬហូបជាមួយក្មេងៗដូចជាពូដែរ?

នីៈ មានពេលខ្លះ គាត់ហៅយើងហូបជាមួយ ។

រតនាៈ គាត់ចូលចិត្តហូបម្ហូបអីដែរ ពូមានដឹងទេ?

នីៈ ម្ហូបខ្មែរយើងហ្នឹងហើយ មានបិស្តឹក ទឹកគ្រឿងអីហ្នឹងណាំ ។

រតនាៈ កាលហ្នឹងពីណាគេធ្វើចុងភៅឲ្យគាត់ពូ?

នីៈ ចុងភៅឲ្យគាត់ហ្នឹង មើល...ប្រពន្ធ តានួន ជា ។

រតនាៈ ឈ្មោះអីដែរពូ?

នីៈ ខ្ញុំភ្លេចឈ្មោះបាត់ទៀតហើយ ។ តែអ្នកដែលជួយដាំស្លរហ្នឹងច្រើនតែជនជាតិ ។

រតនាៈ ជនជាតិអីខ្លះទៅពូ?

នីៈ មានជនជាតិគ្រឹង ជនជាតិជនៀររតនគិរីហ្នឹង យកទៅនៅជាមួយ ។

រតនាៈ អំ! អ៊ីចឹងពូយល់ថាគាត់ចូលចិត្តញ៉ាំម្ហូបជនជាតិ ឬក៏យ៉ាងម៉េចបានជាយក?

នីៈ អត់ទេ ម្ហូបធម្មតា គ្រាន់តែអ្នកនៅជុំវិញគាត់ច្រើនតែយកជនជាតិ ។

រតនាៈ យ៉ាងម៉េចអ៊ីចឹងពូ?

នីៈ អាហ្នឹងប្រហែលជាគាត់ថា ជនជាតិធ្វើការស្មោះត្រង់ណាំ ។

រតនាៈ ចុះក្រៅពីអ្នកធ្វើម្ហូប តើអ្នកធ្វើការផ្សេងៗទៀត ជាជនជាតិដែរឬអត់?

នីៈ ជនជាតិខ្លះ ខ្មែរខ្លះ ។

រតនាៈ ពូមានចាំឈ្មោះខ្លះទេ?

នី: ខ្ញុំអត់ចាំផង ចាំឈ្មោះតែអង្គរក្សក្រោយគាត់ឈ្មោះ ណាង់ តែមិនដឹងជនជាតិអីទេ ជាជនជាតិដែរ ។

រតនា: មកពីរតនគិរីដែរ?

នី: រតនគិរី ។

រតនា: ហេតុអីបានជាគាត់យកអ្នកនៅរតនគិរីហ្នឹងពូ?

នី: ចុះកាលហ្នុង អ្នករតនគិរីទៅធ្វើកងទ័ពជាមួយគាត់ច្រើនណាស់ណា៎ ។ អ្នករតនគិរី មណ្ឌលគិរី រាប់ពាន់នាក់ ។

រតនា: ចុះអ្នកនៅភូមិដីមៀតនេះពូ?

នី: អ្នកដីមៀតនេះក៏ច្រើនដែរ ។

រតនា: ធ្វើអ៊ីខ្លះទៅពូ?

នី: ធ្វើកងទ័ព ។

រតនា: ចុះអ្នកធ្វើការផ្សេង ដូចជាប្រពន្ធ នួន ជា ដែលធ្វើម្ហូបឲ្យគាត់អ៊ីចឹង តើនៅជាមួយគាត់តែម្តង ឬទៅតែពេលធ្វើម្ហូបទេ?

នី: គាត់នៅប្រចាំការធ្វើម្ហូបហ្នឹង ។ គាត់មានផ្ទះផ្សេង តែដល់ពេលដល់ម៉ោងធ្វើម្ហូបគាត់ធ្វើអ៊ីចឹងទៅណា៎ ។ ដល់ហើយបានអ្នកបម្រើហ្នឹង លើកយកទៅឲ្យអ៊ីចឹងទៅ ។

ពីវ៉ន: អ៊ីចឹងបានន័យថា ប្រពន្ធនួនជា ជាមេកាំបិត?

នី: នឹងហើយ មេកាំបិត អាហ្នឹងកាលពីខ្ញុំនៅជាមួយ ខ្ញុំឃើញអ៊ីចឹងណា៎ តែក្រោយពីខ្ញុំចេញពីគាត់មក ខ្ញុំអត់ដឹងទេ ។

រតនា: ពូ កាលហ្នុងហេតុអីបានជាប្រពន្ធ នួន ជា ហ្នឹងបានមកធ្វើចុងភៅឲ្យគាត់អ៊ីចឹង?

នី: អាហ្នឹង កាលរស់នៅជាមួយ តា នួន ជា ជាមួយនឹងគាត់ហ្នឹងតាំងពីដើមមក ចង់និយាយថាតាំងពីការតស៊ូជាប់គ្នារហូត អ៊ីចឹងគាត់យកប្រពន្ធមន្ត្រីហ្នឹង ស្ម័គ្រចិត្តធ្វើម្ហូបឲ្យណា៎ ជាការទុកចិត្តណា៎ ។

រតនា: និយាយអ៊ីចឹងពូទើបតែចាប់ផ្តើមស្គាល់ ប៉ុល ពត ហ្នឹង ពេលដែលពូទៅនៅជាមួយគាត់តែម្តង ឬក៏ស្គាល់តាំងពីមុនមក?

នី: អាហ្នុងរឿងឪពុកខ្ញុំជាមួយនឹងគាត់ទេ ។

រតនា: នឹងហើយ កាលពីមុនមកពូធ្លាប់ឃើញគាត់ជាមួយឪពុកពូ?

នី: បាទ! ដល់ពេលសម័យហ្នុងឪពុកខ្ញុំបញ្ជូនខ្ញុំឲ្យទៅនៅជាមួយគាត់ បញ្ជូនឲ្យទៅរៀន ។

រតនា: តែពូមានដឹងថា យ៉ាងម៉េចបានជាគាត់ស្គាល់ជាមួយឪពុកពូ ហើយស្គាល់នៅពេលណាទេ?

នី: ចាំអត់បានដែរ ប៉ុន្តែជារឿងតស៊ូរបស់គាត់ ព្រោះខ្ញុំកើតដឹងក្តីមកឃើញបដិវត្តន៍ហ្នឹងវាកើតឡើងបាត់ទៅហើយ ។

រតនា: ពូខ្លាចគាត់ទេ ពេលដែលទៅនៅជាមួយគាត់?

នី: អត់ខ្លាចទេ ។

រតនា: ខស្សរាប់ជួបនិយាយលេងជាមួយគាត់ទេ?

នី: និយាយលេងជាមួយគាត់ ហូបនំហូបអី មានស្ករគ្រាប់អីយកឲ្យហូបរហូត ។ កាំភ្លើងបាញ់សត្វបាញ់អីហ្នឹង ខ្ញុំយកប្រើបានធម្មតា ។

រតនា: កាំភ្លើងរបស់គាត់ហ្នឹង?

នី: បាទ!

រតនា: គាត់មានកាំភ្លើងប៉ុន្មានដើមពូ?

នី: គាត់មានកាំភ្លើងច្រើនដែរ អាររបៀបកាំភ្លើងបុរាណណា៎ កាំភ្លើងរបស់កូរ៉េ គាត់រក្សាទុកមើលណា៎ គាត់តាំងដាក់ក្នុងទូកញ្ចក់ ទៅមើលរូប គីម អ៊ីលសុង អីអ៊ីចឹងទៅនៅហ្នឹង ។ អាហ្នឹងជារបស់អនុស្សាវរីយ៍អីមិនដឹង ខ្ញុំក៏មិនដឹងដែរ ។ រូបប្រធានម៉ៅអី មានកាំភ្លើងរបស់ចិនអីអ៊ីចឹង ខ្ញុំចាំមិនអស់ដែរ ។

ពីរ៉ែន: អ៊ីចឹងពូយល់ថា កាំភ្លើងអស់ហ្នឹងគេទិញមកពីស្រុកចិន ឬក៏?

នី: កាំភ្លើងហ្នឹងរបៀបដូចជាតាំងពិពណ៌ទេ មិនមែនយកមកប្រើការអីទេ កាំភ្លើងអាមីសែលអីនោះខ្ញុំអត់ដឹងដែរ អាអាមេអ៊ីចេះនោះ ។

រតនា: គាត់ធ្លាប់ប្រាប់ពូអ្ហែស ថារូបថតអ្នកណា? ម៉ៅ ស៊ីទុង អីបានជាពូដឹង?

នី: ប្រាប់ ។ ហើយដល់ខ្ញុំជាមនុស្សខិល ឃើញចេះតែសួរទៅ កាំភ្លើងអីៗ រូបអ្នកណាៗអី ចេះតែសួរគាត់ទៅ គាត់ប្រាប់ ។

រតនា: ហើយពូនៅជាមួយគាត់រហូតដល់ពេលណាពូ?

នី: នៅរហូតដល់ឆ្នាំ៧៦ គាត់បញ្ជូនខ្ញុំទៅរៀននៅបឹងត្របែក ។ នៅបឹងត្របែកហ្នឹងបានប្រហែលជា៦ខែប៉ុណ្ណឹងទេតាមមើលទៅ ខ្ញុំចាំមិនបានទេ ក៏រឿងមកនៅផ្ទះសំណាញ់ អាកន្លែងខ្ញុំថាមន្ទីរមន្ត្រីរាល់ថ្ងៃ កន្លែងហ្នឹងគេហៅថា ក្រសួងការបរទេស ទៅនៅជាមួយតា អៀង សារី ។

រតនា: ឆ្នាំ៧៦ហ្នឹងដែរពូ?

នី: បាទ! ៧៦ចូល៧៧ហើយ ។

រតនា: កាលហ្នុងចេញពីផ្ទះ ប៉ុល ពត ទៅរៀនហ្នឹងទៅគ្នាប៉ុន្មាននាក់ពូ?

នីៈ ទៅតែខ្ញុំមួយ ។ តា ប៉ន់ គាត់បញ្ជូនទៅតែម្នាក់ឯង តែទៅនឹងវាមានមនុស្សច្រើនទៀត ទៅជួបជុំគ្នា មកតាំងពីទីរួមខេត្តផ្សេងៗណា៎ ។ មានកូនប្រធានតំបន់ផ្សេងៗអី កូនប្រធានស្រុកអីខ្លះទៅជុំគ្នា ទៅរៀនភាសាហ្នឹង ។

រតនាៈ កាលហ្នឹងពីណាគេធ្វើគ្រូបង្រៀន បរទេសឬក៏ខ្មែរ?

នីៈ ខ្មែរ តែខ្មែរមកពីបរទេស ។ ខ្មែរគេហៅបញ្ញាជនដែលចុះមកពីបរទេសណា៎ ។

រតនាៈ ឈ្មោះអីគេពូ?

នីៈ មីងនីន ។

រតនាៈ អ៎! ស្រី ។

នីៈ បាទ! ស្រី ។

រតនាៈ កាលហ្នឹងរៀនតែភាសាអង់គ្លេសមួយមុខទេ?

នីៈ ថ្នាក់ខ្ញុំរៀនភាសាអង់គ្លេស ថ្នាក់គេមានរៀនអេស្ប៉ាញ៉ុល ចិន ។ កាលហ្នឹងមានរៀន អង់គ្លេស អេស្ប៉ាញ៉ុល ចិន តែប៉ុណ្ណឹងទេ តែបីមុខហ្នឹងទេ ។

រតនាៈ ចុះពូរៀនអង់គ្លេសហ្នឹង តើពូជ្រើសរើសខ្លួនឯង ឬក៏គេឲ្យពូទៅរៀនតែម្ដង?

នីៈ ចាត់តាំងឲ្យរៀនតែម្ដង ។ ជំនាន់ហ្នឹងអត់មានដឹងថារើសមិនរើសទេ គេចាត់តាំងឲ្យយើងរៀន គេរុញឲ្យរៀនអី យើងរៀនហ្នឹង ។

សុរិយ៉ាៈ ហើយប៉ុន្មាននាក់ បានរៀន?

នីៈ នៅទីនោះ កុមារប្រហែលជា៣០០នាក់ជាង មួយអគារ ។

រតនាៈ ចុះអ្នកដែលរៀនអង់គ្លេសជាមួយពូ ប្រហែលជាប៉ុន្មាននាក់ដែរ?

នីៈ ប្រហែលជា៦០នាក់ ។

រតនាៈ រៀនភាសាអីច្រើនជាងគេពូ?

នីៈ រៀនអង់គ្លេស ហើយនិងចិនតែម្ដង ច្រើន រៀនអេស្ប៉ាញ៉ុលប្រហែលជាតិចទេ?

រតនាៈ ពូមានស្គាល់កូនអ្នកណាខ្លះទេ ដែលរៀនជាមួយពូ?

នីៈ កូនតាធុច ក៏នៅរៀនជាមួយខ្ញុំដែរ ឈ្មោះ រិន ពីរនាក់បងប្អូនហ្នឹង បងគាត់មិនដឹងឈ្មោះអីទេ ខ្ញុំភ្លេចបានហើយ ។

រតនាៈ កាលហ្នឹងតើវិន័យរស់នៅគេតឹងរឹងដែរឬអត់ពូ? ការហូបចុកអី?

នីៈ ការហូបចុកកាលហ្នឹង ព្រលឹមឡើង ហូបបបរ ថ្ងៃត្រង់ហូបនំប៉័ង ដល់ល្ងាចហូបបាយលាយពោត កាលខ្ញុំរៀននៅបឹងត្របែកណា៎ ។ ដល់ពេលខ្ញុំផ្លាស់មកនៅផ្ទះសំណាញ់នេះបានហូបធម្មតា ។

រតនាៈ ពិបាកជាងរស់នៅផ្ទះ ប៉ុល ពត?

នី:	ពិបាកជាងហើយ ព្រោះនៅកន្លែងហ្នុងវាឆ្ងាយដាច់ស្រយាល ព្រោះយើងនៅក្មេងម្នាក់ឯង យើងចង់ធ្វើអីក៏បានៗណា៎ ។

រតនា:	ចុះពេលពូនៅរៀនហ្នឹង តើគេមានដែលឲ្យពូចេញទៅក្រៅឬអត់?

នី:	នៅរៀនហ្នឹង អត់ទេ អត់ដែលឲ្យចេញទៅណា៎ហួសរង្វង់ហ្នឹងទេ ទៅណាមកណាទាល់តែមានច្បាប់ទម្លាប់ សុំសំបុត្រសុំអី ។ ចង់សម្រាកទៅលេងបងប្អូនអី ទាល់តែមានការអនុញ្ញាតិពីប្រធានមន្ទីរ សុំសំបុត្រ ។

រតនា:	ប្រធានមន្ទីរជាគ្រូបង្រៀនហ្នឹងអ្ហេស?

នី:	អត់ទេ ប្រធានមន្ទីរផ្សេង ឈ្មោះ តាវ៉ែន ដៃស្តាំរបស់ តាប៉ង់ ។

រតនា:	គាត់ជនជាតិដែរ?

នី:	គាត់ខ្មែរ ។

រតនា:	ចុះពូមានដឹងថាហេតុអីបានជាកាលហ្នុងគេឲ្យពូរៀនភាសាអង់គ្លេសទេ?

នី:	រៀនសម្រាប់បកប្រែ ។

រតនា:	បកប្រែអីគេពូ?

នី:	បកប្រែការទំនាក់ទំនងជាមួយបរទេសណា៎ ។ ដល់យើងចេះទៅ ឲ្យរៀនបំពេញនៅបរទេសថែមទៀត ហើយឲ្យបកប្រែ ។

រតនា:	អ៊ីចឹងពូយល់ថាការដែល ប៉ុល ពត បញ្ជូនពូក្នុងចំណោមក្មេងៗទាំងអស់ដែលនៅផ្ទះគាត់ ជាពិសេសពូផ្ទាល់ណា៎ ឲ្យមករៀនភាសាអង់គ្លេស ភាសាចិនហ្នឹង ពូយល់ថាគោលបំណងហ្នឹងដើម្បីអីដែរពូ?

នី:	ខ្ញុំអត់ដឹងដែរអាហ្នឹង សម័យហ្នុងគេថា យកទៅបម្រើប្រទេសជាតិ ឲ្យយើងទៅបម្រើប្រទេសជាតិ ខ្ញុំគ្រាន់តែដឹងប៉ុណ្ណឹងណា៎ គេឲ្យយើងរៀនអី រៀនហ្នឹងទៅ សម័យហ្នុងអ៊ីចឹងអត់មានប្រកែកអីទេ គេឲ្យយើងរៀនអីរៀនហ្នឹងទៅ ។

រតនា:	កាលហ្នុងឪពុកពូដឹងដែរតើ?

នី:	ឪពុកខ្ញុំដឹង ។ តែដល់ឪពុកខ្ញុំស្លាប់ទៅ វាក៏លែងបានទៅបរទេសទៅ មកដល់ផ្ទះកោងហ្នឹងគេរើសកុមារទៅបរទេសណា៎ ។

រតនា:	ពូរៀន៦ខែហ្នឹង រៀនចេះច្រើនដែរ?

នី:	ចេះបានម៉ានិយាយសន្ទនាខ្លះដែរ កាលហ្នុង ព្រោះការបង្រៀនកាលហ្នុងខិតខំណាស់ រៀនព្រឹករៀនល្ងាចៗតែម្តង ។

រតនា:	មួយថ្ងៃរៀនប៉ុន្មានម៉ោងពូ?

នីៈ ក្នុងមួយថ្ងៃរៀន ពេលព្រឹកចាប់ពីម៉ោង៧ដល់ម៉ោង១១ ចេញមកហូបបាយ ហើយម៉ោង១ ចូលរៀនទៀត ។

រតនាៈ ដល់ម៉ោងប៉ុន្មានបានចេញពូ?

នីៈ ម៉ោង៤ ព្រោះប្រញាប់ទៅស្រោចបន្លែទៀត ដាំបន្លែខ្លួនឯង អីខ្លួនឯង ចិញ្ចឹមទាខ្លួនឯង ។

រតនាៈ អីចឹងក្រៅពីរៀនហ្នឹង គេឲ្យកុមារធ្វើការទាំងអស់គ្នា?

នីៈ បាទ! ព្រលឹមឡើងម៉ោង៣ជិតភ្លឺហ្នឹង គឺងើបស្រោចបន្លែហើយ តាមកងណា៎ គេចែកជាកង ជាក្រុមណា៎ ។ ដាំបន្លែរៀងខ្លួន ។

រតនាៈ កាលហ្នុងពូនៅក្នុងកងអីដែរពូ?

នីៈ កងកុមាររួមតែម្តង ។

រតនាៈ ចុះនៅក្នុងកន្លែងហ្នឹង គេមានបែងចែក ដូចថាប្រភេទកុមារខុសគ្នា មួយកងៗ ឬក៏ដូចៗគ្នា ទាំងអស់?

នីៈ គេចែកកង ចែកក្រុម ដូចថាក្រុមមួយ ក្រុមពីរអីចឹងរហូត ។

រតនាៈ ម៉េចបានជាគេចែកអីចឹងពូ?

នីៈ ចែកអីចឹង វាស្រណុកគ្រប់គ្រង និងបញ្ជាកម្លាំងឲ្យធ្វើការណា៎ ។

រតនាៈ មានកងណាខ្លះពូ?

នីៈ អ្ហឺ! មានប៉ុន្មានកង ខ្ញុំអត់ចាំទេ ។

រតនាៈ ចុះកងទាំងអស់នោះ ការរស់នៅ ការហូបចុក ការធ្វើការងារអីដូចគ្នាឬអត់?

នីៈ ពេលហូបបាយ ហូបរួមគ្នាតែម្តង ។

រតនាៈ ចុះពេលធ្វើការ?

នីៈ កន្លែងធ្វើការ គេចែកមុខសញ្ញាគ្នា ។

រតនាៈ ធ្វើការដូចៗគ្នា អត់មានអ្នកខ្លះធ្វើការធ្ងន់ អ្នកខ្លះធ្វើធ្ងន់ ខ្លះធ្វើការស្រាលជាងអីទេ?

នីៈ អត់មានទេ ធ្វើការដូចគ្នាទាំងអស់ នារីក៏ដូចបុរសដែរ កុមារីក៏ដូចកុមារាដែរ ។

រតនាៈ កាលហ្នុង គេមានបែងចែកជាប្រធានកងអីទេពូ?

នីៈ មាន ។ នារីៗ គេនៅក្រុមនារីទៅ បុរសៗគេនៅក្រុមបុរសទៅ ។

រតនាៈ ប្រធានកងពូឈ្មោះអីកាលហ្នុង?

នីៈ ប្រធានកងខ្ញុំឈ្មោះ...ខ្ញុំភ្លេចហើយ វាយូរពេកទៅ ។ ចាំតែបង សែត មួយ ទេ គាត់ជាអនុ ។

រតនាៈ អនុប្រធានកង?

នីៈ បាទ! ស្លាប់បាត់ហើយ ។

រតនាៈ អ៎! អីចឹងក្នុងកងមួយហ្នឹង គេមានបែងចែកជាប្រធាន ហើយមានអនុប្រធាន?

នី៖ បាទ!

រតនា៖ ហើយបន្ទាប់មកបានមានសមាជិក?

នី៖ រៀបចំដូចជាកងទ័ពដែរ កុមារហ្នឹង ។

រតនា៖ មួយកងពូហ្នឹង តើមានប៉ុន្មាននាក់ពូ?

**ផ្នែក B:**

នី៖ ក្រុមពួកខ្ញុំបែកបាក់គ្នាអស់ហើយឥឡូវ មិនដឹងទៅណាអស់ទេ ។

រតនា៖ ពូអត់ដែលជួបអ្នកដែលនៅជាមួយពូទេ?

នី៖ អត់ដែលជួបទេ ។ នៅព្រំដែនថៃខ្លះ ។ កាលពីសម័យសង្គ្រាមហ្នឹង ខ្លះទៅកាន់ទូរលេខ កាន់អី អីចឹងណា៎ ។

រតនា៖ ពូនៅចាំទេ ថាអ្នកណាខ្លះចេញទៅបម្រើការងារខាងអីៗ?

នី៖ ខ្ញុំចាំបានតែមិត្តភក្តិខ្ញុំមួយទេ អាហ្នឹងជាជំនួយការ ប៉ុល ពត ពេលជិតចប់ហើយហ្នឹង ។

រតនា៖ ឈ្មោះអីដែរពូ?

នី៖ ឈ្មោះ អាធឿន ។

រតនា៖ គាត់ទៅនៅជាមួយ ប៉ុល ពត?

នី៖ បាទ! គេទៅកាន់ទូរលេខ ។

រតនា៖ ចុះពូ កាលដែលពូនៅសាលាហ្នឹង ក្រៅពីគេឲ្យធ្វើការងារហ្នឹង តើដែលមានអ្នកណាមួយធ្វើខុស ហើយត្រូវគេហៅទៅអប់រំ ឬក៏ចាប់ខ្លួនអីទេ?

នី៖ ការចាប់ខ្លួន យើងអត់អាចដឹងទេ ឧទាហរណ៍ថា មានអ្នកខុសអីចឹង គេមានឡានគេមកយកណា៎ ហើយយើងអត់ដឹងទេ យើងជាកុមារគេអត់ឲ្យដឹងទេ ។ គេហៅទៅប្រជុំអីចឹង គេយកទៅបាត់ទៅ មានបាត់ខ្លួនអីចឹងដែរ ។

រតនា៖ គេយកឡានមកយក?

នី៖ បាទ!

រតនា៖ ឡានរបៀបម៉េចទៅពូ?

នី៖ ឡានឡុំប្រីគា ។

រតនា៖ ហើយគេដែលប្រជុំដែលអីទេពូ?

នី៖ ប្រជុំ ។

រតនា៖ ប៉ុន្មានថ្ងៃគេប្រជុំម្តងពូ?

នីៈ មួយល្ងាចគេប្រជុំម្តង គេហៅថាប្រជុំជីវភាពណ៎ា ។ ប្រជុំជីវភាព គេចាត់ចែងកម្លាំងប្តូរវេនគ្នា ដាំបន្លែដាំអីអីចឹង អាហ្នឹងគេហៅប្រជុំជីវភាព ។

រតនាៈ អ្នកណាគេជាអ្នកមកប្រជុំ?

នីៈ មេក្រុម មេកងយើងហ្នឹង ដល់ពេលបានដប់ថ្ងៃអីចឹង គេប្រជុំរួមម្តង ។

រតនាៈ ចុះពូវិញ ដែលធ្វើខុសអីទេ ពេលនៅហ្នុង?

នីៈ អត់ដែលទេ ។

រតនាៈ ចុះពូ អ្នកដែលបាត់ខ្លួន សុទ្ធតែអ្នកដែលបានធ្វើខុសអ្ហេស?

នីៈ មិនដែលឃើញខុសអីដែរ តែបែបមានការសង្ស័យអីពាក់ពន្ធអីមិនដឹង យើងអត់ដឹងដែរ ឬមួយក៏ឪពុកម្តាយខាងណោះមានរឿងអីក៏មិនដឹង អាហ្នឹងវាច្រើនអីចឹង ។

រតនាៈ កាលហ្នុងពូមានបានដឹងដំណឹងពីឪពុកម្តាយពូទេ កាលនៅរៀននៅបឹងត្របែកហ្នឹង?

នីៈ មិនសូវបានដឹងប៉ុន្មានដែរ ។

រតនាៈ ហើយឪពុកពូដែលមកលេងពូទេ?

នីៈ មិនដែលមកទេ ។

រតនាៈ ចុះពូដែលជួប ប៉ុល ពត ទេកាលហ្នុង?

នីៈ អត់ដែល ។

រតនាៈ ចុះពូដែលសុំច្បាប់ទៅលេងឪពុកម្តាយពូ?

នីៈ ចង់និយាយពីច្បាប់ចេញពីកន្លែងហ្នឹង គេមិនងាយឲ្យចេញ ការនៅរៀនហ្នឹង គេជម្រុញឲ្យយើងខំរៀនតែម្តង ។

រតនាៈ ពូដែលសុំគេមកទេ?

នីៈ អត់ដែលសុំផង មិនហ៊ានសុំតែម្តង ។

រតនាៈ ចុះអ្នកផ្សេងៗទៀត តើដែលមានអ្នកណាសុំគេចេញ ឬក៏បានចេញមកទេពូ?

នីៈ អត់ដែលដែរ នៅហ្នុងប៉ុន្មានឆ្នាំមិនដែលមានអ្នកណាហ៊ានសុំចេញទេ ។

រតនាៈ ពូនៅបឹងត្របែកហ្នឹងប៉ុន្មានឆ្នាំដែរ?

នីៈ នៅបឹងត្របែកហ្នឹង នៅអត់យូរទេ តាមខ្ញុំចាំនៅមិនដល់មួយឆ្នាំទេ?

រតនាៈ កាលហ្នុងពូទៅនៅឆ្នាំ៧៦អ្ហេស?

នីៈ បាទ! ចុង៧៥ ដើម៧៦ ចន្លោះហ្នឹង ។ ដល់៧៧ ខ្ញុំមកនៅផ្ទះកោងវិញ ។

រតនាៈ អ៎! អីចឹងពេលពូទៅនៅបឹងត្របែកហ្នឹងឆ្នាំ៧៦ហើយ ហើយ៧៧បានពូមកនៅផ្ទះកោង?

នីៈ បាទ!

រតនាៈ កាលហ្នុងម៉េចបានជាគេបញ្ជូនពូមកនៅផ្ទះកោងវិញ?

នីៈ គេដូរមន្ទីរណា៎ ទាំងអស់គ្នាហ្នឹងមកនៅផ្ទះកោង ។

រតនាៈ អ៎! អីចឹងដូរមន្ទីរ៨៧០ហ្នឹង?

នីៈ អត់ទេ ៨៧០ហ្នឹងកន្លែងមន្ត្រីគេទេអាហ្នឹង ។ កន្លែងកងកុមារខ្ញុំដូរពីបឹងត្របែកហ្នឹងមកនៅផ្ទះកោង ។

រតនាៈ ផ្ទះកោងដែលមានដាំផ្កាចំប៉ីនៅពីមុខមួយជួរហ្នឹងអ្ហេស?

នីៈ បាទ! នឹងហើយ អាផ្ទះសំណាញ់ណា៎ ពីដើមជាកន្លែងមន្ត្រីទាហានណា៎ ។

រតនាៈ ចុះពេលដែលពូមកនៅហ្នឹង មកតែក្រុមកុមារពូចាស់ហ្នឹង ឬក៏មានអ្នកផ្សេងមកនៅជាមួយដែរ?

នីៈ ម៉ាអង្គភាពកុមារដដែលហ្នឹង ។

រតនាៈ ចុះគ្រូបង្រៀនអីមានដូរទេកាលហ្នុង?

នីៈ មកទាំងអស់ អត់មានដូរទេ ។

រតនាៈ ប្រធានមន្ទីរអីក៏មកដែរ?

នីៈ ប្រធានមន្ទីរដូរ ។

រតនាៈ ដូរទៅអ្នកណាវិញពូ?

នីៈ ដូរជាក់ពូរិន ។

រតនាៈ គាត់អាយុប៉ុន្មានដែរពូ?

នីៈ គាត់អាយុប្រហែល៣០ជាង ។

រតនាៈ ចុះប្រធានមន្ទីរពូចាស់ ទៅណាទៅពូ?

នីៈ គេចាប់ ។

រតនាៈ មូលហេតុអីបានជាគេចាប់ពូ?

នីៈ អត់ដឹងដែរ ។

រតនាៈ ហើយពូបានឃើញពេលគេចាប់គាត់ទេ?

នីៈ គេយកឡានមកយក បានន័យថាចាប់ហើយ ឡានហ្នឹងសម្រាប់តែមកយកមនុស្ស ។

រតនាៈ គេចាប់មុនពេលផ្លាស់មក ឬក្រោយ?

នីៈ ចាប់មុនពេលផ្លាស់ ចាប់គាត់ហ្នឹងហើយ ផ្លាស់មកបណ្តោយ ។

រតនាៈ ចុះពូដឹងថាគេចាប់គាត់យកទៅណាទេ?

នីៈ ខ្ញុំអត់ដឹងដែរ ។

រតនាៈ អីចឹងពេលដែលពូមកដល់ផ្ទះកោងហ្នឹង ពូនៅរៀនភាសាអង់គ្លេសដដែល?

នីៈ បាទ រៀនភាសាអង់គ្លេសដដែល ។ រៀនរហូតដល់ឆ្នាំ៧៨ ដល់វៀតណាមចូលហ្នឹងបានដិះរទេះភ្លើងរត់ទៅស្វាយស៊ីសុផុន ។

រតនាៈ ចុះការរស់នៅរបស់ពូ បន្ទាប់ពីការដួរមន្ទីរហ្នឹង តើមានការខុសប្លែកពីមុនប្អត់ ទាំងការរស់នៅការហូបចុក ការធ្វើការអីពូ?

នីៈ ផ្លាស់ពីហ្នឹងមកនេះ ការងាររអត់សូវធ្វើទេ មានតែបោសផ្ទះនិងរៀន កុមារទាំងអស់ណា៎ ។ យូរៗអ៊ីចឹងគេហៅថាហត្ថកម្មម្ដងអ៊ីចឹង គេស្នើកងកុមារហ្នឹងទៅណាក៏បានដែរ មានមន្ទីរណាគេចង់ជម្រះស្មៅឬក៏ត្រួសព្រៃ ត្រួសអី គេយកកុមារហ្នឹងទៅជួយក្នុងរយៈពេលពីរបីថ្ងៃអ៊ីចឹងមកវិញ អាហ្នឹងដូចអត់មានអីពិបាក ។ ដាំស្ពៃដាំអី អត់មានដាំអីទៀតទេ ។

រតនាៈ កាលហ្នឹងពូទៅធ្វើការនៅកន្លែងណាខ្លះទៅ?

នីៈ កាលហ្នឹងទៅបោសនៅអាកន្លែងស្ថានទូតអាមេរិកហ្នឹងម្ដង ។

រតនាៈ កន្លែងហ្នឹងជាកន្លែងអីគេពូ?

នីៈ អត់ដឹងគេធ្វើកន្លែងអីទេ តែឃើញដឹងថាជាកន្លែងស្ថានទូតអាមេរិកណា៎ នៅចំការមន ។ ហើយបន្ទាប់មកទៀតគេស្នើកម្លាំង ខាងសេដ្ឋកិច្ចនៅប្រាំងចំរេះហ្នឹងទៅធ្វើត្រីបានពីរដងរហូតដល់រត់ចេញពីភ្នំពេញ ។

រតនាៈ ចុះនៅផ្ទះកោងហ្នឹង ពូដែលបានសុំគេមកលេងផ្ទះដែរទេ?

នីៈ អត់ដែលសុំចេញទេ ដែលលួចទៅលេងបង ។

រតនាៈ បងពូធ្វើការនៅឯណា?

នីៈ បងខ្ញុំធ្វើការនៅខាងលិចដេអិនបច្ចុប្បន្នហ្នឹងណា៎ ។

រតនាៈ បងពូឈ្មោះអីពូ?

នីៈ បងវ៉ាន ហ្នឹង គាត់នៅធ្វើការជាមួយប្រពន្ធ គាអៀង សារី ហ្នឹង ។

រតនាៈ ចុះក្រែងថាជីបូង គាត់នៅបើកឡានឲ្យឪពុកពូ?

នីៈ ខ្ញុំនិយាយអត់អស់ ក្រោយពេលខ្ញុំមករៀនហ្នឹង ឪពុកខ្ញុំស្លាប់ ហើយប្រពន្ធអ៊ំ អៀង សារី ហ្នឹង គាត់យកមកបើកឡានឲ្យគាត់ ។

រតនាៈ កាលហ្នឹងម៉េចបានពូដឹងថា ឪពុកពូស្លាប់ បើពូចេញមករស់នៅសាលាហ្នឹង?

នីៈ ខ្ញុំអត់ដឹងទេ ទាល់តែយូរបានខ្ញុំដឹង គេអត់ប្រាប់ទេ ទាល់តែយូរបានខ្ញុំដឹង ។

រតនាៈ ពូដឹងតាមរយៈអី?

នីៈ ទាល់តែខ្ញុំមកលេងបងខ្ញុំ ។

រតនាៈ កាលហ្នឹងគាត់ប្រាប់ពូថាម៉េចខ្លះ?

នីៈ គាត់អត់និយាយច្រើនទេ គាត់គ្រាន់តែថា ប្អូនឯងមិនបាច់ខូចចិត្តទេ ខំរៀន ឪពុកយើងស្លាប់ហើយ តែប៉ុណ្ណឹង អត់មាននិយាយអីទេ ។

រតនាៈ តែក្រោយៗមកទៀត ពូដឹងរឿងដែលឪពុកពូស្លាប់ដែរតើអ្ហេស?

នីៈ ដឹង ។

រតនាៈ ដូចថាដឹងពីមូលហេតុដែលគាត់ស្លាប់ ស្លាប់នៅឯណាអី?

នីៈ កាលហ្នុងខ្ញុំអត់បានសួរពីមូលហេតុផង តែក្រោយមកបានដឹង ។ កាលដែលស្លាប់ហ្នឹង គាត់ស្លាប់នៅផ្ទះជិតចតុមុខណាំ ។

រតនាៈ កាលហ្នុងជាកន្លែងអីគេពូ?

នីៈ ខ្ញុំអត់ស្គាល់ទេកន្លែងហ្នឹង កាលពីជំនាន់ហ្នុងគេហៅមន្ទីរតំបន់១០៥ ប្រចាំភ្នំពេញ ។

រតនាៈ ជាកន្លែងដែលគាត់ធ្វើការហ្នឹង?

នីៈ បាទ! គាត់ស្លាប់ហ្នឹង បងប្រុសខ្ញុំហ្នឹងនៅជាមួយថ្ងៃហ្នុងនោះ ។

រតនាៈ បងឈ្មោះ វ៉ាន ហ្នឹងអ្ហេស?

នីៈ បាទ! បងវ៉ាន ហ្នឹង ។ ហើយយកអ៊ំ ខាំភូន ហ្នឹង គាត់ចោទណាំ យកមកឲ្យអគ្គការនៅភ្នំពេញហ្នឹង អាហ្នឹងតាមខ្ញុំសាកសួរបងប្អូនអ្នកនៅជាមួយហ្នឹងណាំ គេថា ឪពុកខ្ញុំហ្នឹងទៅសុំមកអប់រំ ។

រតនាៈ សុំអ៊ំ ខាំភូន ហ្នឹងអ្ហេស?

នីៈ បាទ! ដល់ហើយ គាត់ក៏នៅប្រាជ្ញលេងជាមួយបងប្រុសខ្ញុំ គាត់គ្រុនៗ ដល់ពេលហ្នុង អ៊ំខាំភូនហ្នឹងបបួលឡើងទៅដេកនៅលើបានមានខ្យល់ តាមនិរសាគាត់និយាយណាំ ។ ដល់គាត់ទៅដេកនៅលើ ទទួលដល់ម៉ោង១១, ១២ ដល់ម៉ោងបាយ អគ្គរក្សគាត់ដែលដាំបាយឈ្មោះពូស៊ីហ្នឹងគាត់ក៏មកហៅៗសួរបងខ្ញុំថា គាត់នៅដេកនៅលើ ដល់ឡើងទៅលើស្រាប់តែឃើញខ្មោចអ៊ំខាំភូន ហ្នឹងនៅទទឹងទ្វារ ។

រតនាៈ បានន័យថាឪពុកពូហើយនឹងខាំភូនហ្នឹងស្លាប់ទទឹមគ្នា?

នីៈ អត់ទេ ឪពុកខ្ញុំស្លាប់លើគ្រែតើ ។

រតនាៈ ស្លាប់ដោយមូលហេតុអីទៅពូ?

នីៈ ស្លាប់ដោយគាត់យកអាដំបងគន្លឹះទ្វារយើងកាលពីជំនាន់ហ្នុង វាមានអាដែកអ៊ីចេះណាំ ដែកប៉ុនមេជើងហ្នឹង ។

រតនាៈ អ្នកណាគេវាយអ្នកណាពូ?

នីៈ អ៊ំខាំភូន ហ្នឹងវាយឪពុកខ្ញុំ ដល់ពេលវាយហើយ គាត់យកកាំភ្លើងឪពុកខ្ញុំហ្នឹងបាញ់ខ្លួនគាត់កាំភ្លើងតូចអាប្រាហាណាំ ។

រតនាៈ ចុះពេលហ្នុងអត់មានអ្នកណាឮសម្លេងគាត់ឈ្លោះគ្នា ឬសម្លេងកាំភ្លើងទេ?

នីៈ អត់ពុទេកាំភ្លើងហ្នឹង ។

រតនាៈ អ៎! កាំភ្លើងហ្នឹងកាំភ្លើងរបស់ ឡាំង?

នីៈ កាំភ្លើងរបស់ឪពុកខ្ញុំតើ កាំភ្លើងនៅក្មេក ។ គាត់អត់មានកាំភ្លើងទេ គេដកអស់ហើយ មានតែឪពុកខ្ញុំទេ ដែលមានកាំភ្លើង ។ ហើយគាត់យកកាំភ្លើងឪពុកខ្ញុំហ្នឹងបាញ់ខ្លួនគាត់ទៅណា៎ បានស្លាប់មាត់ទ្វារហ្នឹងអាលើឡាវលើហ្នឹង ។

រតនាៈ ម៉េចបានជាគាត់សម្លាប់ឪពុកពូ?

នីៈ កាលហ្នុងខ្ញុំអត់ដឹងដែរ ខ្ញុំនៅក្មេងខ្ញុំអត់ដឹងទេ ។

រតនាៈ ចុះបងពូអត់មាននិយាយប្រាប់ពូពីមូលហេតុទេ?

នីៈ ដឹងតែថា គាត់ហ្នឹងក្បត់ គេនិយាយតែអីចឹងកាលហ្នុង ដឹងតែថា អាំខាំភូន ហ្នឹងក្បត់សម្លាប់ឪពុកខ្ញុំ ។

រតនាៈ កាលហ្នុងអ្នកណាគេជាអ្នកចាប់អាំ ខាំភូន ហ្នឹង?

នីៈ សាន អ្នកចាប់ ។ សាន ប្រធានកងពល៩២០ ។

សុរិយ៉ាៈសាន ហ្នឹងមានឈ្មោះអីមួយទៀតទេ?

នីៈ ... ។

សុរិយ៉ាៈសាន ហ្នឹងក្រោយទេអ្ហី ក្រែងឈ្មោះ ឈិន អ្ហេស អនុគាត់ឈ្មោះ សយ ណា៎ ប្រធានកងពល៩២០ ។

នីៈ តាសាន ហ្នឹងហើយ មេកងពល៩២០ ធំជាងគេ ។

សុរិយ៉ាៈពេលក្រោយមកអ្ហេស? ប្រហែលជាមេបន្ទាប់ពីចាប់តា ឈិន តា សយ រួចទេដឹង ។ តាឈិន តាសយ ឆ្នាំ៧៧ជិត៧៨គេចាប់ ។

នីៈ មានតែ តាសាន ហ្នឹងហើយធំជាងគេនៅកងពល៩២០នោះ ។

សុរិយ៉ាៈតែតាឈិន ហើយនិង តាសយ នោះ?

នីៈ តាសាន ហ្នឹងគាត់នៅពីលើ គេហៅថា នយោបាយណា៎ ។

សុរិយ៉ាៈគាត់នៅរហូតអ្ហេស?

នីៈ បាទ! នៅរហូតទាល់តែទៅនៅអន្លង់វែង ។

សុរិយ៉ាៈប្រធានស្នងការនយោបាយប្រចាំកងពល៩២០?

នីៈ បាទ!

រតនាៈ ចុះអាទំនប់កងពល១ហ្នឹង ទំនប់កងពល៩២០ហ្នឹងអ្ហេស?

នីៈ បាទ! នឹងហើយ ។

សុរិយ៉ាៈពួកហ្នឹងអ្នកសាងសង់អ្ហេស?

នី:	បាទ!

សុរិយ៉ា:បងមានដឹងថា មានរឿងអីបានជាគេចាប់កង៩២០ហ្នឹងទេ ចាប់តា ឈិន តាសយ?

នី:	ខ្ញុំអត់ដឹងទេ ខ្ញុំមិនចាំទេ ។

សុរិយ៉ា:អ៊ីចឹងតួនាទីរបស់កងពល៩២០ហ្នឹង ផ្នែកទ័ពនៅមណ្ឌលគិរីហ្នឹងខ្លាំងតែម្តងអ្ហេស?

នី:	បាទ! ខ្លាំង ។

សុរិយ៉ា:អាចចាប់ដល់គណតំបន់បានទៀត?

នី:	ចាប់បាន ទាល់តែបញ្ជាពីតំបន់ដែរ គណតំបន់ហ្នឹងធំជាងតាសានទៀត ។

សុរិយ៉ា:អ៊ីចឹង ឡាំង ហ្នឹងធំជាង តាសាន ទៀត?

នី:	បាទ! ធំជាង ។

សុរិយ៉ា:អ៊ីចឹងដែលថាចាប់អ្នកណាៗហ្នឹង ត្រូវតែមានបញ្ជាពី ឡាំង សិន បានចាប់បានអ្ហេស?

នី:	នឹងហើយ ទាល់តែឯកភាពពីហ្នុងមកដែរ ។

សុរិយ៉ា:តែពេលដែលគេចាប់ ខាំភូន ហ្នឹង?

នី:	កាលចាប់ អ៊ំខាំភូន ហ្នឹងមានបទបញ្ជាផ្ទៃក្នុងផ្សេងទៀត ខ្ញុំអត់ដឹងទេ ។

សុរិយ៉ា:ពីភ្នំពេញមកអ្ហេស?

នី:	បាទ! ពីភ្នំពេញមក ។

រតនា:	កាលហ្នុងគេចាប់គាត់ពីណាទៅពូ?

នី:	ចាប់ពីស្រុកកោះញែកទៅ ចាប់នៅផ្ទះបែកបាក់ហ្នឹងកាលហ្នុង ផ្ទះថ្ម មន្ទីរខេត្តណា៎កាលហ្នុង ។

សុរិយ៉ា:មន្ទីរក១៧ណា៎ មន្ទីរខេត្ត?

នី:	បាទ!

សុរិយ៉ា:ឥឡូវនៅសល់ថ្មបន្តិចៗណា៎?

នី:	នឹងហើយ នៅថ្ម ។

រតនា:	គេចាប់ដោយសារគេចោទថាក្បត់?

នី:	នឹងហើយ គេថាក្បត់ ។

រតនា:	ចុះពូមានដឹងថាពេលហ្នុងគាត់ធ្វើសកម្មភាពអីទេ បានជាគេចោទគាត់ថាក្បត់?

នី:	អត់ដឹងទេ ។

រតនា:	ចុះហេតុអីបានជាឪពុកពូទៅសុំគាត់មកអ៊ីចឹង?

នី:	អាហ្នឹងគេហៅថា មនោសញ្ចេតនាចង់អួសទាញគាត់អីអ៊ីចឹងណា៎ ចង់សុំយកមកធ្វើការវិញ ព្រោះគាត់ពីរនាក់ហ្នឹង ទីមួយសាច់ញាតិ ទីពីរពួកម៉ាកតាំងពីជំនាន់នៅរៀនជាមួយគ្នា ។

រតនា:	គាត់ត្រូវជាបងប្អូនជាមួយឪពុកពូដែរអ្ហេស?

នីៈ	គាត់ហ្នឹងខ្សែខាងម្ដាយខ្ញុំទេ ខ្សែឆ្ងាយដែរ ។ ហើយគាត់ជាមួយឪពុកខ្ញុំហ្នឹងត្រូវជាពួកម៉ាក ពួកម៉ាកស្លាប់រស់តែម្ដង ស្រឡាញ់គ្នាដូចបងប្អូនអីចឹង ព្រោះចាស់ៗជំនាន់ហ្នុងតែពួកម៉ាក ពួកម៉ាកមែនទែនហ្នឹង មិនមែនដូចជាក្មេងៗឥឡូវ ពួកម៉ាកបបរទេ (សើច) ។

រតនាៈ ពួកម៉ាកបោកគ្នា?

នីៈ	បាទ! ពួកម៉ាកបោកគ្នា ចាស់ៗពីដើមអត់បានទេ សុទ្ធតែចាក់ឈាមផឹក ។

រតនាៈ ចុះកាលពេលឪពុកពូស្លាប់ហ្នឹង ម្ដាយពូនៅឯណាដែរពូ?

នីៈ	ម្ដាយខ្ញុំស្លាប់មុនឪពុកខ្ញុំទៀត?

សុរិយ៉ាៈឆេះផ្ទះហ្នឹងអ្ហេស?

នីៈ	បាទ! ឆេះផ្ទះនៅក១៧ចាស់ណាំ ត្រើយខាងណោះច្បារ ។

សុរិយ៉ាៈអ៎! ក១៧ចាស់នៅខាងណោះច្បារទេ?

នីៈ	បាទ!

សុរិយ៉ាៈចុះផ្លាស់ប្ដូរគ្នាទៅនៅអាផ្ទះថ្មនោះជំនាន់ណាំ ឆ្នាំណាំ?

នីៈ	ឆ្នាំ៧៥ ។

រតនាៈ ក១៧ចាស់កន្លែងដែលម្ដាយពូស្លាប់ហ្នឹងនៅកន្លែងណាំពូ?

នីៈ	កន្លែងចាស់ គេហៅភូមិដើមស្វាយឥឡូវ ។

រតនាៈ ឃុំ?

នីៈ	ឃុំស្រែហ៊ុយ ។

រតនាៈ ស្រុកអីគេពូ?

នីៈ	ស្រុកកោះញែក ។

រតនាៈ កាលហ្នុងម្ដាយពូធ្វើការអីដែរនៅហ្នុង?

នីៈ	ម្ដាយខ្ញុំជាប្រធានសមាគមនារីហ្នឹងហើយ ជាប្រធានសហករណ៍អ្ហេស ។

រតនាៈ កាលហ្នុងគាត់ស្លាប់នៅឆ្នាំណាពូ?

នីៈ	ភ្លើងឆេះផ្ទះឆ្នាំ៧៤ ឆ្នាំប្អូនពៅខ្ញុំកើត ។

រតនាៈ ពូកាលហ្នុង ឆេះដោយសារមូលហេតុអី ដោយគេលួចដុតឬក៏?

នីៈ	ឆេះដោយសារសាំងចាក់ចង្កៀងទេ មិនមែនដោយសារគេលួចដុតទេ ប្រេងកាតយន្ដហោះណាំ ។

រតនាៈ កាលហ្នុងពូដឹងដែរ?

នីៈ	ខ្ញុំនៅហ្នឹងដែរ ។

រតនាៈ ពូនៅផ្ទះចាស់ហ្នឹងដែរ?

នី៖ បាទ! នៅហ្នឹង តែខ្ញុំនៅផ្ទះបាយរួមណ៎ា ។

សុរិយ៉ា៖ ថាអ្នកណាគេយកសាំងដុតកាលហ្នុង?

នី៖ សាំងហ្នឹងនៅក្រោមគ្រែណ៎ា ផ្ទះយើងធ្វើជាផ្ទះទាមណ៎ា ហើយធ្វើគ្រែធំអីចឹងណ៎ា ហើយសាំងហ្នឹងនៅក្រោម ដល់ពេលគាត់លើកសាំងមកលើពីរនាក់ក្មួយគាត់ឈ្មោះ បងហឿង ។ គាត់យកសាំងហ្នឹងមកចាក់ចង្កៀង ម៉ែខ្ញុំអ្នកចាក់ ហើយបងហឿង អ្នកអុចដង្កៀងមើលអីចេះ ដល់ពេលដាក់ទៅជិតធាប ឆេះផ្ទះអស់រលីង ។

រតនា៖ កាលហ្នុងស្លាប់អ្នកណាខ្លះពូ?

នី៖ ស្លាប់ម្ដាយខ្ញុំមួយ ហើយកូនកំព្រាមួយដែលគាត់យកមកចិញ្ចឹម ។

រតនា៖ ដែលក្មួយដែលកាន់ចង្កៀងឲ្យនឹងអ្ហេស?

នី៖ អត់ទេ, បងស្រីហ្នឹងអត់ស្លាប់ទេ គាត់រត់រួច ។ គ្មានអ្នកណាហ៊ានចូល បើសុទ្ធតែភ្លើង សុទ្ធតែគ្រាប់ពេញផ្ទះ ឡានចេះយកចេញដុតទាន់ កុំអីឆេះទាំងឡានទៀត ឡានរុញចេញតាំងពីភ្លឺ អាឡានអត់អាគុយណ៎ា ។

សុរិយ៉ា៖ ចុះទ័ពតំបន់ពីណាគេធ្វើមេ?

នី៖ ទ័ពតំបន់អ្ហេស? ពូវៀង ។

សុរិយ៉ា៖ វៀង ហ្នឹងត្រូវជាអីដែរ?

នី៖ វៀង ហ្នឹងត្រូវជាក្មួយបង្កើតឪពុកខ្ញុំ ។

សុរិយ៉ា៖ ឈ្មោះអី វៀង?

នី៖ ប៊ុន វៀង ។

សុរិយ៉ា៖ ប៊ុន វៀង ហ្នឹងជាប្រធានកងពលប្រចាំតំបន់តែម្ដង?

នី៖ បាទ!

សុរិយ៉ា៖ កងពលតំបន់ហ្នឹងជា៨០១អ្ហ៎?

នី៖ ១០៥ ។

សុរិយ៉ា៖ តំបន់ហ្នឹងវា១០៥ហើយ តែឈ្មោះកងពល វាមាន៨០១?

នី៖ មិនមែនទេ ៨០១ខាងរតនគិរី ។ ប្រធានយោធាតំបន់ហ្នឹង គេដាក់ជាប់ដល់ឥឡូវ ១០៥ហ្នឹងរហូត នៅអន្លង់វែងហ្នឹង ។

សុរិយ៉ា៖ អ៎! ដេរ្ងទេ តា ប៊ុន វៀង ។ គាត់នៅរស់ដល់ឥឡូវទេ?

នី៖ គាត់ស្លាប់បាត់ហើយហ្នឹង ។ ស្លាប់គេស្ទាក់បាញ់នៅអន្លង់វែង ។

សុរិយ៉ា៖ ក្រោយអាពតអ្ហេស?

នី៖ សម័យយើងមុនអន្លង់វែងសមាហរណកម្មនេះ ។ គេហៅគាត់ឡើងទៅរៀន គេបាញ់តាមផ្លូវ ។

សុរិយ៉ាៈ តួនាទីកងតំបន់ហ្នឹង ខុសគ្នាពីតួនាទីកងពល៩២០យ៉ាងម៉េចទៅ ព្រោះមណ្ឌលគិរីមានដល់ទៅពីរ ហ្នឹង?

នីៈ អាមួយដូចយើងសឹករងឥឡូវហ្នឹងអីចឹងណា៎ ។

សុរិយ៉ាៈ អ៎! ដូចវាចុះក្រោម ។

នីៈ ៩២០ មជ្ឈិមគេទម្លាក់មកឲ្យនៅហ្នឹងណា៎ ។ អីចឹងបានថា ការងារហ្នឹងវាមានបទបញ្ជាផ្ទៃក្នុង វាមានអាក្រោមឱវាទរបស់តំបន់ ។ គាត់ហ្នឹងនៅក្រោមឱវាទរបស់តំបន់ តែរឿងពិសេសមាន បទបញ្ជាផ្ទៃក្នុង ។ គេអាចទាក់ទងត្រង់ទៅ៨៧០ ។

សុរិយ៉ាៈ ហើយ តាវៀង នេះបានតែផ្ទៃក្នុងតំបន់ទេ?

នីៈ បាទ!

សុរិយ៉ាៈ ការពារសន្តិសុខអីអីចឹង ។ អីចឹងបានជំនាន់ចាប់ ផាន ឃន អីហ្នឹង ពួក៩២០អ្នកចាប់ឬមួយក៏ ពួក វៀង អ្នកចាប់?

នីៈ ទេ! ខ្ញុំអត់ដឹងដែរ ។

តួយៈ ពួក តាឡាន់ ពួកតំបន់១០៥ ។

សុរិយ៉ាៈ តាឡាន់ ក្រោយ តាវៀង ទេ?

នីៈ ទ័ពតំបន់គេរុញទៅព្រំដែន ។

សុរិយ៉ាៈ តាឡាន់ ប្រធានសន្តិសុខអ្នកចាប់អ្ហេស?

នីៈ បាទ! តាឡាន់ តាឡេង ។

សុរិយ៉ាៈ ចុះក្រែងប្រធានសន្តិសុខ សុភា ទេអេស?

នីៈ សុភា កាន់ខាងអីពុកស? សួរគាត់នោះបានច្បាស់ ។ ដីផ្ទះគាត់នៅដល់ឥឡូវដែរ ត្រឹះស៊ីម៉ង់ ។ ពូសុភា កាន់ខាងអីកាលហ្នុង?

តួយៈ កាន់ខាងសន្តិសុខដែរ តែខាងអ្នកទោសដែលគេហៅថា អតីតទាហាន ឬក៏អតីតអ្នកទោសរបប ពួកកុម្មុយនិស្តអីនោះ ប្រគល់លើ សុភា គ្រប់គ្រង ។

រតនាៈ អីចឹងពូ តាំងពីពេលដែលពូបែកមករៀនហ្នឹង ពូអត់ដែលបានជួបឪពុកពូទេ រហូតដល់ឪពុកពូ ស្លាប់?

នីៈ អត់ដែលបានជួបទេ ។

រតនាៈ ចុះពេលដែលពូមកនៅផ្ទះកោងហ្នឹងហើយ តើពូដែលជួប ប៉ុល ពត អីទៀតទេ?

នីៈ តាំងពីចេញពីផ្ទះកោងហ្នឹងទៅ ខ្ញុំមិនដែលបានជួបទេ រហូតដល់ខ្ញុំរត់ទៅនៅព្រំដែនហ្នឹង បានជួប ឆ្នាំ១៩៨៣ជួបគាត់ម្តងទៀត ។ ៨៣ជួបម្តង មកឆ្នាំអ៊ុនគាត់ចូលនេះ ឆ្នាំពៅប៉ុន្មាន?

សុរិយ៉ាៈ ៩៣ អ៊ុនគាត់ចូល ។

នី: នឹងហើយ ឆ្នាំ៩០គត់ខ្ញុំជួបគាត់នៅថ្មពួក ។

សុរិយ៉ា: ជួបតាអីម៉ិញ?

នី: ប៉ុល ពត ។

រតនា: គាត់ចំណាំពូបានទេ?

នី: គាត់ចំណាំអត់បានទេ ពេលជួបហ្នឹង ។

រតនា: ចុះពូមានបាននិយាយជាមួយគាត់ទេ?

នី: គាត់និយាយជាមួយខ្ញុំមុន គាត់ហៅខ្ញុំឲ្យបើកឡានចេញ ។ ឡានគាត់ទិញមកឲ្យណា៎ កន្លែងអន្លង់វែង ភាពណា៎ នៅភ្នំឆត្រ ។ កាលជួបលើកទីមួយហ្នឹង គាត់ស្គាល់ គាត់សួរគេណា៎ ។ តាហាក់ តាម ខ្ញុំមកជួបគាត់ គាត់ឲ្យនាឡិការមួយ ។

រតនា: គាត់អត់ហៅពូឲ្យមកធ្វើការជាមួយគាត់ទេ?

នី: ខ្ញុំមកធ្វើការជាមួយតា អឿន សារី ហើយ ។ ខ្ញុំនៅកាន់វិទ្យុទាក់ទង ។

រតនា: និយាយអីចឹងកាលពូនៅរៀន រៀនដល់ឆ្នាំ១៩៧៨ ដល់ពេលវៀតណាមចូលមកតែម្តង?

នី: ដល់វៀតណាមចូលតែម្តង ។ ដល់ពេលឆ្នាំ៨២ ខ្ញុំនៅស្រុកម៉ាឡៃបច្ចុប្បន្នណា៎ មានបើកសាលារៀនទៀត កាកបាទក្រហមជួយ ។ បើកសាលារៀនដល់ថ្នាក់ទី៧ថ្មីយើងហ្នឹងណា៎ ខ្ញុំរៀនដល់ថ្នាក់ទី៥ ។

សុរិយ៉ា: និយាយអីចឹងខ្ញុំឃើញក្រដាសមួយដែលគេសរសេរដៃដាក់ថា កងការពារហ្នឹងគេហៅក្រុមកប៉ុន្មានអីប៉ុន្មានទេ នៅជុំវិញមន្ទីរ ប៉ុល ពត ហ្នឹង សុទ្ធតែក្មេងៗបងប្អូនជនជាតិតែម្តងណា៎ យកពីនេះទៅតែម្តង យកទៅការពារណា៎ ។ ក្នុងចំណោមហ្នឹងប្រហែលជាមានឈ្មោះបងដែរហើយមើលទៅ មានបញ្ជីរបស់គេណា៎ ។

នី: អត់ដឹងដែរ ។

សុរិយ៉ា: បងដឹងថា នៅក្បែរៗ ប៉ុល ពត ហ្នឹង កងការពារ អ្នកដែលនៅក្បែរៗយាមគាត់ហ្នឹង ដែលជាជនជាតិហ្នឹង តើមានឈ្មោះអីខ្លះទៅ?

នី: ខ្ញុំចាំអត់បានទេ ព្រោះខ្ញុំនៅក្មេងដែរ អត់មានចាប់អារម្មណ៍ ។

រតនា: តែគ្រាន់តែដឹងថាមានជនជាតិនៅក្បែរៗ ការពារគាត់?

នី: បាទ! ចាំបានតែ ណង់ មួយទេ ដែលនៅក្រោយ អាហ្នុងខ្ញុំជួបក្រោយទេ ។

រតនា: កងការពារគាត់ដែរ?

នី: បាទ! រត់ទៅនៅថៃ យកប្រពន្ធថៃ ។ យកលុយប៉ុន្មានសែនបាតទៅនៅថៃ ទៅនៅស៊ីសាកេត ។

សុរិយ៉ា: អីចឹងចំពោះរឿងដែលចាប់ ដូចយើងពិភាក្សាគ្នាអម្បាញ់ម៉ិញ ចាំមើលណា៎សាច់រឿងដែលកើតមកមុនដំបូង តាមដែលខ្ញុំដឹង មុនដំបូងគេចាប់ តាសយ ហើយតាឈិន អាហ្នឹងពួកកងពលត្រូវ

គេចាប់ បន្ទាប់មកមានរឿងគេចាប់...មិនទាន់ចាប់ ដាន យន ទេ ក៏កើតមានរឿង គាស្វាយ គាកាស៊ីនេះ មានដឹងដែរ? ចាប់មុន ដាន យន ទៀតអ្ហេស?

នី: ចាប់ក្រោយទេអ្ហី?

គួយ: ខាំភូន ចាប់ក្រោយ ។

សុរិយ៉ា: ស្វាយ, កាស៊ីអី ចាប់ក្រោយ ខាំភូន ក្រោយ ដាន យន ទេ?

នី: កាស៊ី, ស្វាយ នឹងចាប់មុន ។

សុរិយ៉ា: កាស៊ី, ស្វាយ នឹងមុន ជួន មុន ដាន យន ទៀត?

នី: នឹងហើយ ។

សុរិយ៉ា: កាស៊ី, ស្វាយ នេះឯង ដែលគោប់ បន្ទាប់ពីចាប់កងពល៩២០មក ឈិន ហើយនិង សយ នឹងមក ក៏មានចាប់ កាស៊ី ចាប់ ស្វាយ ចោទថារឿងទាក់ទងជាមួយវៀតណាម ។ ហើយ បន្ទាប់មកបានផ្ទុះរឿងឈ្លោះគ្នា ឡាំង ហើយនិង ខាំភូន ។ បន្ទាប់មកបានមានចាប់អ្នក ក្រោមៗ ដូចជាអ្នកខាងពេទ្យ បូឡៃ, បូលី, ដាន យន តៗគ្នាមកនឹង?

នី: នឹងហើយ ។ ដល់តែស្លាប់ឪពុកខ្ញុំពីប ចាប់ផ្ដើមចាប់ពាសវាលតែម្ដងអាហ្នឹង អត់មានចាប់ធម្មតា ទេអាហ្នឹង ។

សុរិយ៉ា: នេះ ទាំងតា ចាន់ គួយ ទាំងអី មួយខ្សែទៅ ទាំងឪពុកគាត់អី ។

នី: ទាំងបងខ្ញុំហ្នឹង បងដែលស្លាប់មួយនោះ ឈ្មោះ បងប៊ួន អីនឹង ទាំងពូ សាវ៉ាត ពូអីហ្នឹង គេ ចាប់ផ្ដើមសើរើយកមកដាក់កន្ទែងលត់ដំអស់ហើយអាហ្នឹង ក្រោយមកហ្នឹង ។

សុរិយ៉ា: កាលហ្នឹងខ្ញុំឮថា ខ្សែបងប្អូនឯងនឹងអ្ហេស? សុទ្ធតែខ្សែ គេថា ខ្សែឡាំងចាប់ខ្សែខាងខាំភូន ។ បន្ទាប់ពីឮថា ខាំភូន អ្នកវាយ ឡាំង ស្លាប់ទៅ ខ្សែតា ឡាំង ចាប់ខ្សែ ខាំភូន អីចឹងអ្ហី?

នី: នឹងហើយ ទៅអីចឹងហើយ ។ តាសារុន ហ្នឹងឡើងជាគណតំបន់ ។

សុរិយ៉ា: សារុន ហ្នឹង គេខ្សែខាង ឡាំង អ្ហី?

នី: បាទ!

សុរិយ៉ា: តាចាន់ស៊ី នៅឯណោះ គាត់ប្រាប់ខ្ញុំដែរ សារុន ហ្នឹងត្រូវជាប្អូនជីដូនមួយ ឡាំង អ្ហេស?

នី: អត់ទេ ត្រូវជាពូ ។

សុរិយ៉ា: ពូជិតអ្ហេស អីចឹងកាត់ចារាយអីដែរអត់ទេ?

នី: ពូឆ្ងាយទេ ។ ឡាវកាត់ចារាយមិនដឹង ឡាវសុទ្ធមិនដឹង ។

សុរិយ៉ា: សារុន ឡើងមក ឮសូរថាខ្លាំងតែម្ដង ចាប់ខ្ទេចខ្ទី ចុះ សារុន អ្ហេសអ្នកបញ្ជាចាប់?

នី: មួយរយៈខ្លីទេ មិនបានយូរទេ មិនទាន់បានធ្វើអីផងនឹង មិនទាន់បានលើកទំនប់លើកប្រឡាយអី នឹងគេផងហ្នឹង ។

គួយៈ ពីរនាក់ហ្នឹងស្លាប់ក្មេក គិតតែរឿងចាប់និងវាយចោលតែម្តង ។

សុរិយ៉ាៈបន្ទាប់ពី ឡាំង និង ខាំកូន វាយគ្នាស្លាប់ទៅ បានអ្នកណាអ្នកបញ្ជាទ័ពឲ្យចាប់ ផាន ឃន អីនឹង តើអ្នកណាគេអ្នកបញ្ជាទៅ?

នីៈ អាហ្នឹងធ្លាក់លើ តាសាន ហើយនឹង ខាងចុះផ្ទាល់តែម្តង ។

សុរិយ៉ាៈពេលហ្នឹង សារុន មិនទាន់បានឡើងផង មើលទៅ ។

នីៈ តាសាន តែម្តង តាមក្ត តាឡាន់ គាត់និយាយប្រាប់ខ្ញុំ ។ ប្រើកម្លាំង តាសាន តែម្តងពេលហ្នឹង ។

គួយៈ តាសាន គាត់អត់ដឹងខ្សែរយៈទេ មានតែ តាសារុន អ្នកដឹង ។

រតនាៈ តាសារុន ហ្នឹង មុននឹងគាត់ឡើងជំនួសឪពុកពូហ្នឹង តើគាត់ធ្វើអីគេពូ?

នីៈ សួរគាត់នោះបានដឹង ។

គួយៈ ធ្វើចៅហ្វាយស្រុកពេជ្រចិន្តា ស្រុក-រ៣ ។

សុរិយ៉ាៈស្រុក-រ៣ហ្នឹងស្រុកពេជ្រចិន្តា ចុះរ៤? កោះញែកហ្នឹងអ្វី?

នីៈ រ១ កោះញែក, រ៣ ពេជ្រចិន្តា, រ៤ កែវសីម៉ា ។

សុរិយ៉ាៈចុះរ២?

នីៈ រ២ រ៣នៅហ្នឹងដែរ វាបូកចូលគ្នា ។ គេជម្លៀសប្រជាជនមកពីភ្នំមកហ្នឹង គេដាក់រ២ជាមួយ រ៣ហ្នឹងចូលគ្នា ។

សុរិយ៉ាៈរ២ រ៣ហ្នឹង កែវសីម៉ា?

នីៈ រ២ រ៣ អូររាំង ពេជ្រចិន្តា ។

រតនាៈ រាប់តាមលំដាប់លំដោយ រ១ កោះញែក, រ២ រ៣?

នីៈ សែនមនោរម្យ អូររាំង ។

សុរិយ៉ាៈចុះរ៤?

នីៈ កែវសីម៉ា ។

រតនាៈ មានន័យថាម៉េចពូ រ១ រ២ រ៣ ហ្នឹង "រ" ហ្នឹងគេតំណាងឲ្យអីគេ?

នីៈ គេសម្គាល់ឈ្មោះស្រុកណា ។

សុរិយ៉ាៈខ្ញុំធ្លាប់សួរគាត់ម្តងដែរ គាត់អត់ដឹងដែរ ។ មើលខ្ញុំសូមសរុបឡើងវិញ តាមដែលបងដឹង សម្លាប់គ។គ្នាមកម៉ិញ ស្វាយ, កាស៊ី អីមុនគេ ហើយគ។មករហូតមកដល់ចាប់ខាំកូន ឪពុកបងវាយគ្នាអីហ្នឹង តាមដែលខ្ញុំមើលឯកសារមកទាក់ទងគេចោទថាវៀតណាម តែតាមការយល់ឃើញរបស់បងវិញ ថាតើអាចមានលទ្ធភាពថា ជនាន់អាពតហើយមានអ្នកដែលត្រូវជាមួយ

វៀតណាម ប្រុងធ្វើរដ្ឋប្រហារអីចឹងមែន ឬក៏មកពីអ្នកដឹកនាំហ្នឹងឈ្លោះគ្នា ហើយចោទគ្នាថាមានទំនាក់ទំនងអីជាមួយវៀតណាម ហើយរាយការណ៍ទៅលើ ហើយខាងលើចាប់ទៅសម្លាប់?

នីៈ តាមខ្ញុំយល់ ចោទគ្នាហ្នឹងច្រើនជាង ។

រតនាៈ ចោទគ្នាថាវៀតណាម?

នីៈ បាទ! តាមពិត អ្នកដែលធ្វើពេលហ្នឹងណា៎ មនោគមន៍វិជ្ជាតាំងពីក្មេងដល់ធំ ធ្វើអីគឺធ្វើហ្នឹងហើយ ស្មោះត្រង់ណាស់ លុះត្រាតែអ្នកថ្នាក់លើទេ ដែលចេះ ដឹងសាច់រឿងច្រើនជាង ដឹងពីមជ្ឈដ្ឋានខាងក្រោមច្រើនជាង ។ នៅពេលហ្នឹងប្រជាពលរដ្ឋយើង អ្នកដែលចេះល្មមៗណា៎ សូម្បីតែចង់ចេញទៅណាក៏ពិបាកដែរ តែតាមពិតបើសិនជាទៅ បានដូចគ្នា តែដល់ពេលមនោគមន៍វិជ្ជាគ្របដណ្តប់ទៅ វាទៅជារឿងដូចនៅក្នុងអណ្តូង អានេះបើតាមការយល់របស់ខ្ញុំណា៎ ។ ចុះបើសិនដូចឥឡូវនេះ បើយើងចង់ទៅវៀតណាម ទៅបានណា៎ ឲ្យប៉ូលីសព្រំដែនចាប់ដៃគ្នាក៏នៅតែទៅបានដែរ ។ តែសម័យនោះ មនោគមន៍វិជ្ជាគ្នាវាមិនអាចទៅណាបាន វាស្មោះត្រង់ពេកជាមួយបក្សណា៎ ។

សុរិយ៉ាៈ អីចឹងពួកហ្នឹងស្មោះត្រង់ណា៎ បើថា អាការដែលចោទថាវៀតណាមអី មកពីដណ្តើមគ្នាធ្វើធំ ហើយចោទគ្នា រាយការណ៍ទៅថ្នាក់លើ?

នីៈ បាទ! នឹងហើយ ។

សុរិយ៉ាៈ ដូចតា ចាន់ គួយ និយាយម៉ិញអីចឹងថាអារឿងនំកន្ទក់ រឿងអីនៅក្រោយផ្ទះស្វាយអី ចេះតែចោទទេ មែនទេ?

នីៈ គ្រាន់តែចោទហ្នឹង ។

សុរិយ៉ាៈ ហើយពូនិយាយថានៅក្រោយផ្ទះ ស្វាយ អីហ្នឹងដែលថាគេប្រើ តាស្វាយ ទៅចាប់ហ្នឹង កាលហ្នឹង តាស្វាយ តួនាទីគាត់ជាចៅហ្វាយស្រុកអ្វី?

នីៈ ចៅហ្វាយស្រុក ។

សុរិយ៉ាៈ ចៅហ្វាយស្រុកកោះញែកតែម្តង?

នីៈ នឹងហើយ ។

**កាសែ្សតទីពីរៈ**

**ផ្នែក A:**

..............

សុរិយ៉ាៈ អីចឹងវាយពួកម៉ុងតាញ៉ាហ្នឹង យកទៅសម្លាប់នៅត្រពាំងគៀនហ្នឹងអ្ហេស?

គួយៈ អ្ហេស! ត្រពាំងនៅភូមិស្រែហ៊ុយហ្នឹង ។

សុរិយ៉ា៖ពួកហ្នឹងពូថាវង្វេងព្រៃ វង្វេងអីចូលមកទេអ្ហី?

តូយៈ ការពិតនោះ វាទៅរក លន់ ណុល, អ៊ិន តាំ អីទេពួកហ្នឹងនោះទេ ។

សុរិយ៉ា៖ទៅរកយ៉ាងម៉េច? ទៅរកវាយពួកហ្នឹង?

តូយៈ ទៅរកខ្មែរគេហ្នឹង ខ្មែរអាមេរិកណាំ ។

នីៈ អ៎! ពួងឯងនិយាយអីចឹង ខ្ញុំនឹកឃើញហើយកាលហ្នឹង ។ កាលចាប់ស្រីហ្នុងអ្ហេស? នៅមន្ទីរ សំងាត់នេះ ។

តូយៈ ទេ! មន្ទីរសំងាត់ហ្នឹង ពួកឯទ័ពទេ ។

នីៈ គេថា មានស្រីស្អាតម្នាក់ឯណានោះ ។

សុរិយ៉ា៖ស្រីស្អាតនឹងខ្មែរម៉ុងតាញ៉ាតាមរក លន់ ណុល ទេអ្ហេស?

នីៈ ... ។

សុរិយ៉ា៖ពូថាពួកម៉ុងតាញ៉ាមកម៉ិញដែល ស្វាយ ចាប់យកទៅ ហើយខាងលើគេឲ្យសម្លាប់ហ្នឹង គឺពួក ហ្នឹងមកហ្នឹង ក្នុងបំណងរក លន់ ណុល រកអីទេអ្ហេស?

តូយៈ រក លន់ ណុល រក អ៊ិន តាំ អីណោះទេ ។

សុរិយ៉ា៖រកខ្មែរគេអ្ហេស?

តូយៈ រកខ្មែរគេ ។

សុរិយ៉ា៖កាលហ្នុងពូជានិរសារបស់ ភ៉ា ។ ហើយ ភ៉ា ហ្នឹងជាអនុចៅហ្វាយស្រុកកោះញែក?

តូយៈ ហើយសួរចម្លើយនឹង គ្មានកូនទាហាន គ្មានចៅហ្វាយណាទេ មានតែខ្ញុំទេកាន់កាំភ្លើងយាមទ្វារឲ្យ ហ្នឹង ឈរនៅផ្ទះខ្ពស់ហ្នឹង ។

សុរិយ៉ា៖យាមទ្វារពួកដែលចាប់បានហ្នឹងអ្ហេស?

តូយៈ នឹងហើយ ។ ហើយគេសួរចម្លើយនៅលើផ្ទះហ្នឹង ខ្ញុំនៅហ្នឹង គ្មានពីណាហ៊ានទៅជិត យួនៗគ្មាន ហ៊ានទៅក្បែរអី គេដកកាលហ្នុងហើយ ។

សុរិយ៉ា៖អីចឹងបងជានិរសាគាត់ ហើយតាមយាមហ្នឹងច្បាស់តែម្តង?

តូយៈ ច្បាស់ហើយ ។

សុរិយ៉ា៖ប្រហែលប៉ុន្មាននាក់?

តូយៈ ប្រុសបី ស្រីម្នាក់ ។

សុរិយ៉ា៖អ៎! តែបួននាក់ហ្នឹង?

តូយៈ បួននាក់ ។

សុរិយ៉ា៖ជនជាតិអី?

តូយៈ ជនជាតិរដែរពីរនាក់ ហើយពីរនាក់ទៀតកូនកាត់វៀតណាម ។

សុរិយ៉ាៈ អត់មានស្គាល់ឈ្មោះទេអ្នស?

តូយៈ កាលហ្នុំងមានស្គាល់ឈ្មោះ តែឥឡូវវាភ្លេចហើយ វាយូរពេកហើយ ។ អ៊ំ! គេយកទៅវាយចោល ។

សុរិយ៉ាៈ ខ្ញុំមើលឯកសារ ជំនាន់ក្រោយមកមានគេចាប់បានទៀត ប្រហែលជាពូជីងទេ ឈ្មោះ ខៀវ ជុំ គេថាជាហ្វុលរ៉ូខ្មែរដែរ ចាប់យកដល់ទួលស្លែងដែរ ។

តូយៈ មកតាមច្រកណា?

សុរិយ៉ាៈ ដាក់ថាចូលមណ្ឌលគិរី ។ មួយទៀត ឈ្មោះ អ៊ី ប្អូន ។

តូយៈ អត់មាន ។

សុរិយ៉ាៈ អត់ឮសួរឈ្មោះទេ ។ ឈ្មោះ អ៊ី ចាម មានមកច្រើនណាស់ ពួកហ្នឹងគេចាប់បាន ។

តូយៈ ពួកហ្នឹងមានតែពួកកងពលចាប់បាន ពួក៩២០ ព្រោះថា ពួក៩២០នៅតាំងពីកន្ទុយនាគ ៩២០ ឬក៏ ៩០២ រតនគិរី ។ ប្រហែលជាពីរនាក់ មកពីទ័ពមជ្ឈិមហើយនឹង ទ័ពតំបន់នៅក្នុងចាប់ពីនរើមក ។ ក្រៅពីទ័ពតំបន់នៅមានទ័ពមជ្ឈិម ទ័ពតា កែវ សាន ។

សុរិយ៉ាៈ និយាយអ៊ីចឹង ខ្ញុំចង់សួរពីរឿងទូទៅវិញណា ពីរឿងសហគមន៍ជនជាតិយើងវិញណា ។ ជនជាតិហ្នឹងមានឡាវផង មានជនជាតិផ្សេងៗទៀតនៅជាមួយគ្នាណា តើកាលហ្នុង កាលពីដើមមកតាំងពីមុនមកជំនាន់អាពតហ្នឹង ភូមិដីមៀងហ្នឹងភាគច្រើនជាឡាវតែម្តង?

តូយៈ កងទ័ពភូមិដីមៀតហ្នឹងមានឡាវ ។

សុរិយ៉ាៈ តែចង់និយាយថាពេលមុនជំនាន់អាពតហ្នឹង ភាគច្រើនមានឡាវនៅក្នុងនេះ?

តូយៈ ឡាវ ។

សុរិយ៉ាៈ ចុះភូមិក្បែរៗហ្នឹង តើមានជនជាតិអីផ្សេងៗទៀតទេ?

នីៈ ភូមិជនជាតិព្នង ។

សុរិយ៉ាៈ កោះមយើលហ្នឹងអ្នស?

នីៈ នឹងហើយ ។ កោះមយើល មានគ្រោល ព្នង ចារាយ ។

សុរិយ៉ាៈ ហើយសាសនាខុសៗគ្នាដែរ?

តូយៈ ប៉ុន្តែ បើមកនៅជុំវិញហ្នឹង ជនជាតិមួយចំនួនថាពាក់កណ្តាលចុះ ៥០ភាគរយគេគោរពតាមសាសនាព្រះពុទ្ធទៅហើយ ពួកឡាវដឹកនាំអ៊ីចឹង គេធ្វើតាម ។ ហើយ៥០ភាគរយហ្នឹងគេធ្វើតាមប្រពៃណីគេ កាប់ក្របី សែនព្រេន ។

សុរិយ៉ាៈ អ៊ីចឹងមុំជុំវិញពាមដីមៀត ពេញណងឃីលីក កោះមយើលអីហ្នឹង ដោយសារមានមេដឹកនាំជាឡាវអ៊ីចឹង ភាគច្រើនគេចូលតាម៥០ភាគរយ ៥០ភាគរយទៀតគេកាន់តាមរបស់គេទៅ ។

ហើយសហគមរស់នៅតាំងពីដើមមក ក្នុងនាមជាជនជាតិអ៊ីចឹង មិនដែលមានការឈ្លោះប្រកែកគ្នាប្រកាន់ជាតិនេះ ជាតិនោះអី មានដែលទេ?

តូយៈ អត់ទេ អត់មានទេ ។

សុរិយ៉ាៈ ចុះចំពោះចលនា វាដូចជាចលនារបស់ហុលរ៉ូ ដូចថាចលនាខ្មែរក្រហមចុះ ទាំងបងនេះ គាត់ជាកូនរបស់ ឡាំង ក៏ដោយ ពូ ចាន់ តូយ ក៏ដោយ ពូយល់ថា ពូទាំងពីរនាក់យល់ថា រឿងខ្មែរក្រហមហ្នឹងជារឿងបណ្តាលមកពីបញ្ហាអី តើបណ្តាលមកពីបញ្ហាជនជាតិមួយស្អប់ជនជាតិមួយ ឬក៏បណ្តាលមកពីដណ្តើមអំណាច ឬក៏បណ្តាលមកពីវណ្ណៈអ្នកមានអ្នកក្រ ឬក៏បណ្តាលពីស្អីបានជាកើតអារឿងចលនាហ្នឹង ។

នីៈ គឺរឿងអ្នកមានអ្នកក្រ ពីដើមបំផុត នៅក្នុងឯកសារមាននិយាយពីរឿងអ្នកមានជិះជាន់អ្នកក្រ ។ ការកេងប្រវ័ញ្ចណាំ ដល់អ៊ីចឹងប្រជាពលរដ្ឋក្រីក្រផ្ទុះឡើង វាមានការឈឺចាប់ មានការធ្វើបាបកាលពីជំនាន់ហ្នុងណាំ ។

សុរិយ៉ាៈ ខ្លាំងតែម្តង ទ្រឹស្តីអ្នកមានអ្នកក្រហ្នឹង?

នីៈ បាទ! ទ្រឹស្តីហ្នឹង ។

សុរិយ៉ាៈ ដោយសារជំនាន់ហ្នុងមានការជិះជាន់អ្នកមានអ្នកក្រអីអ៊ីចឹងទៅ ដល់ពេលឃោសនាទៅចូលតែម្តង?

នីៈ បាទ!

សុរិយ៉ាៈ អ៊ីចឹងស្រុកខ្មែរយើងបើនិយាយទៅ មិនដែលមានជម្លោះរឿងជនជាតិទេ ។ បើខាងវៀតណាមនោះមានហុលរ៉ូមានអី មិនអ៊ីចឹងអ្ហេស?

នីៈ បាទ!

សុរិយ៉ាៈ ឈ្លោះគ្នាដណ្តើមដី ដណ្តើមអីឯណាណោះ?

នីៈ បាទ!

សុរិយ៉ាៈ បើខ្មែរយើងមិនដែលមានទេ?

នីៈ អត់មានទេ ។

សុរិយ៉ាៈ អ៊ីចឹងបងយល់ថាស្ថានភាពឬក៏បរិយាកាសស្រុកខ្មែរយើង បណ្តាលមកពីស្អីបានជាយើងរស់នៅបានសុខសប្បាយជាងអ្នកជិតខាងយើងណាំ ដូចវៀតណាមអី មានរឿងហុលរ៉ូឈ្លោះគ្នាដណ្តើមទឹកដីជនជាតិអីនីង នៅថៃឥឡូវហ្នឹងមានផ្នែកខាងត្បូងឈ្លោះគ្នាអីអ៊ីចឹង ហើយនៅឥណ្ឌូនេស៊ីមានឈ្លោះគ្នាដណ្តើមដីដណ្តើមអីអ៊ីចឹង ពីបញ្ហាជនជាតិណាំ ហើយស្រុកខ្មែរយើងបានសុខសប្បាយ ពូយល់ថា បណ្តាលមកពីស្អីបានជាស្រុកខ្មែរយើងរស់នៅបានសុខសប្បាយ មិនដែលមានរឿងជនជាតិ?

នីៈ បច្ចុប្បន្ននេះអ្ហែស?

សុរិយ៉ាៈបច្ចុប្បន្នក៏ដូចជាមុនអាពត មិនដែលឈ្លោះគ្នាទេរឿងជនជាតិ ។ បងថា ឈ្លោះគ្នាកាលមុន ចូលព្រៃចូលអីរឿងវណ្ណៈទេ រឿងអ្នកមានអ្នកក្រទេ អត់ប្រកាន់ជនជាតិទេ តែវាសុខសប្បាយ រឿងជនជាតិនឹងជនជាតិហ្នឹងរស់នៅជាមួយគ្នា សាសនាខុសគ្នាក៏នៅជាមួយគ្នាដែរ ដូចចាម ខ្មែរអី ព្រះពុទ្ធសាសនា ឥស្លាមអី បងប្អូនញ្ញូងអីមានអបិយជំនឿ កាប់គោ កាប់អារក្ស អ្នកតា អីក៏មិនដែលឈ្លោះគ្នាដែរ ។ ចុះបងយល់ថាបណ្តាលមកពីស្អីបានជាស្រុកខ្មែរយើងរស់នៅបាន សុខសប្បាយជាមួយគ្នាអីចឹង?

នីៈ អានេះតាមខ្ញុំយល់ បើនិយាយពីបច្ចុប្បន្ននេះណា៎ អាហ្នឹងតាមការឃើញជាក់ស្តែង មកពីខ្មែរ យើងអត់សូវប្រកាន់សាសនាប៉ុន្មានទេ បច្ចុប្បន្នណា៎ ដូច្នេះពីមុនមកពិតមែនតែប្រកាន់សាសនា មែន ខ្មែរ ជនជាតិណា៎ក៏ដោយដែលចេញចូលគឺមានការរាប់អានគ្នា មានស្គាល់គ្នា ចងមិត្ត ចង ម្រាក់អីអីចឹងណា៎ ។

សុរិយ៉ាៈអាហ្នឹងជាចរិតរបស់ខ្មែរតែម្តង?

នីៈ អាហ្នឹងជាចរិតរបស់ប្រទេសយើង និយាយអីចេះចុះ ។

សុរិយ៉ាៈចរិតរបស់ប្រទេសយើងហ្នឹង គឺមិនសូវប្រកាន់សាសនា ប្រកាន់អីទេ រាប់អានតែម្តង?

នីៈ បាទ! ការរាប់អានគ្នាអីចឹងទៅ ។ ដល់ពេលឥឡូវរដ្ឋាភិបាលយើងបើកទូលាយ បើកឲ្យមានសិទ្ធិ រវាងជនជាតិមួយទៅជនជាតិមួយ ដូច្នេះការរស់នៅកាន់តែល្អជាងមុនទៅទៀត ដូច្នេះមានខ្មែរ មកយកជនជាតិ មានជនជាតិទៅយកខ្មែរ អាហ្នឹងកាត់សាសន៍គ្នាទៅវិញទៅមក ។ បើថាដូចពី ដើមវិញ គ្រាន់តែថាអ្នកដែលមកនៅហ្នឹង គឺមានអ្នកធានាអីចឹងណា៎ អ្នកដែលចង់មកយកប្រពន្ធ កូននៅហ្នឹង ទាល់តែមានអ្នកធានា ទុកទៅកំពង់នៅ ដល់ឥឡូវគេចង់និយាយថាបើកសិទ្ធិ ដល់ អីចឹងខ្មែរយើងអត់មានទំនាស់រឿងជនជាតិទេ ចាមមកក៏បាន ខ្មែរក៏បាន ។ ខ្ញុំឃើញសាសនាក៏ គេយកពីរដែរ បច្ចុប្បន្នហ្នឹង សាសនាព្រះពុទ្ធក៏គេរាប់អាន សាសនាព្រះសែនក៏គេនៅតែប្រកាន់ គេនៅយកមកដើរជាមួយគ្នា ឥឡូវណា៎ ។ ដូចថាយើងសែនហើយ និមន្តលោកមកសូត្រ ដូច្នេះ ជនជាតិយើងទៅអីចឹងហើយឥឡូវនេះ នៅក្នុងវត្តនេះ កោះមយើលក៏ដោយ អីក៏ដោយ ពី ដើមឡើយអត់ដែលមានលោកទៅសូត្រទេ ។

រតនាៈ អីចឹងចូលគ្នាអស់ហើយ?

នីៈ បាទ! ឥឡូវចូលគ្នាហើយ សែនហើយនិមន្តលោកសូត្រ ឲ្យមានតែមានលោកគឺគេនិមន្តហើយ ។

សុរិយ៉ាៈឥឡូវហ្នឹង នៅពាមជីមៀតយើងមានប៉ុន្មានរយនាក់ ប៉ុន្មានរយគ្រួសារហើយ ក្តាប់បានទេ ។

នីៈ ក្មួយយកសៀវភៅមកហើយ ចាំបន្តិច ចាំខ្ញុំទៅយក ។

សុរិយ៉ាៈមានជាបញ្ជីតែម្តង?

នីៈ បញ្ជី អានេះសរុបចំនួនប្រជាជន ។

រតនាៈ ពូមានសរុបចំនួនជនជាតិឡាវនៅក្នុងភូមិហ្នឹងទេ?

នីៈ អ្ហ! សរុបដែរតែមិនដឹងនៅត្រង់ណា មិនទាន់បានរើ ។

រតនាៈ អីចឹងចាំជួយរកមើល ៗ ព្រោះអាហ្នឹងពិបាករកបដែរ ទាល់តែប៉ូលីសបានដឹង ។

នីៈ បាទ!

សុរិយ៉ាៈពួកខ្ញុំអីចេះទេ សរសេរពីប្រវត្តិភូមិហ្នឹង ចង់ដឹងថា កាលពីមុនហ្នឹង ត្រកូល ខាំ ដាន ហ្នឹងមក រស់នៅហ្នឹងមុនគេ កកើតភូមិ ឃុំឡើងមក ហើយកាលមុនដំបូង តាម តាចាន់ តូយ និយាយ អម្បាញ់មិញថា តែបួនគ្រួសារទេ?

នីៈ បាទ!

សុរិយ៉ាៈហើយ តា ដាន នេះ គាត់ជាឪពុករបស់មីងនេះ មីងជាកូនពៅរបស់ ដាន ហើយ នៅសល់ តែមួយ ។ ហើយបងគាត់ ដាន ឃន ហើយ ជួន នឹងឯង ។ ខាំ ដាន ហ្នឹង គាត់មកពីសុវណ្ណ ខេត្តតែម្តង គាត់មកនៅហ្នឹងអ្ហី?

ខាំៈ ចា!

សុរិយ៉ាៈគាត់ជាមនុស្សទីមួយតែម្តង ។ ហើយកាលគាត់មកនៅ បើមើលដើមស្វាយនេះវិញ បើគិតទៅ ១០០ឆ្នាំទេដឹង?

នីៈ មិនដល់ទេ ៨០ឆ្នាំ ។

សុរិយ៉ាៈជំនាន់ឪពុកស្តេចហ្នឹង ជំនាន់ឪស្តេចសីហនុ?

នីៈ បាទ! មកនៅទាក់ដីរណា ។

សុរិយ៉ាៈមកនៅមុនដំបូង តា ចាន់ តូយ ថាបួនគ្រួសារអ្ហី? បួនហ្នឹង តា ខាំ ដាន តែមួយគ្រួសារ ហ្នឹង?

តូយៈ តា ខាំ ដាន ហើយនិងបងប្អូនគាត់ហ្នឹង ហើយជាមួយយាយខ្ញុំ ។

សុរិយ៉ាៈតែមកពីសុវណ្ណខេត្តតែមួយហ្នឹង?

តូយៈ អត់ទេ យាយខ្ញុំមកពីសិដា នៅឯណោះ ។

សុរិយ៉ាៈអ៎! នៅជិតនេះទេ?

តូយៈ ... ។

ខាំៈ គាត់មកនៅបានពីរបីឆ្នាំ គាត់ទៅយកបងប្អូនគាត់មកនៅទីនេះទៀត អីចឹងណា ។

សុរិយ៉ាៈអ៎! ចេះតែគ ៗ មក ។

ខាំៈ អើ! ចេះតែតៗមកៗ ដល់នេះទៅ បងប្អូនគាត់ល្បីថាបងរកទាក់ដំរីបាន បង់ត្រីត្រង់នេះបាន លើកឆ្នាំងដាក់លើភ្លើង ហើយទៅបង់យកមកធ្វើសម្លរបាន មួយភ្លេតៗនឹងណា៎ៗ ឥឡូវមិនដឹងទៅរកឯណា ត្រីនោះៗ អ៊ីចឹងណា៎ បងប្អូនគាត់ចេះតែមកៗរហូតអ៊ីចឹងៗ

រតនាៈ អ៊ីចឹងមីងដឹងរឿងដែលគាត់ចូលមកដំបូងៗនឹងច្បាស់ៗ

ខាំៈ អើ! ខ្ញុំកើតនៅទីនេះ មកពីក្រ ដីក្របានមកហ្នឹង មិនមានស្អីធ្វើស្រែធ្វើស្អី ដល់ខែស្ងួតនោះដឹកក្របីរកស៊ីតាមភ្នំរហូត???ៗ

សុរិយ៉ាៈ នៅសុវណ្ណខេត្តហ្នឹងអ្ហែស?

ខាំៈ នៅឡាវហ្នុងៗ នៅស្រុកស្រែដូចយើងអ៊ីចេះណា៎ អ្នកទីក្រុងគេមិនធ្វើទេៗ

សុរិយ៉ាៈ គាត់ថាម៉ិញ ដោយសារនៅសុវណ្ណខេត្តហ្នឹងស្រុកហ្នឹងក្រ ពិបាករកស៊ី ដីធ្លីអីពិបាករស់នៅ បានគាត់មកនៅទីនេះៗ

រតនាៈ អ៊ីចឹងភូមិនេះ ដំបូងបំផុតអត់មានមនុស្សរស់នៅទេ ទាល់តែ ដាន ខាំ គាត់មកដល់?

នីៈ ព្រៃឮងៗ

ខាំៈ ជនជាតិព្នងនៅៗ

សុរិយ៉ាៈ ចុះមីង ម៉ិញមីងដាក់ឈ្មោះដូចតាអ៊ីចឹង? ដាន ខាំ អ្ហែស?

ខាំៈ ចា៎!

សុរិយ៉ាៈ ហើយដល់តានោះ មិនឈ្មោះ ដាន ខាំ?

ខាំៈ ចា៎! កាំ ដានៗ កាំ ទេៗ

តួយៈ កាំ នឹងមានន័យដូចថា ព្រានអ៊ីចឹងណា៎ ភាសាឡាវនោះៗ

នីៈ គេហៅថា តាព្រានៗអ៊ីចឹងណា៎ៗ

សុរិយ៉ាៈ អ៎! កាំៗ ហ្នឹងប្រែថាអ្នកពូកែទាក់ដំរីអីអ៊ីចឹងអ្ហែស?

ខាំៈ ចា៎!

នីៈ ដូចដាង គេហៅថា ដាងៗ អាឈ្មោះដើមបាត់ហើយ ដល់បាត់ទៅ ទៅជាព្រានវិញៗ

ខាំៈ តាអី ឪពុកហ្នឹងៗ

នីៈ ឪពុកឪពុករបស់គាត់ ជីតាគាត់ឈ្មោះ តាលួងៗ

..........................................

រតនាៈ ពូឥឡូវខ្ញុំចង់សួរពូ ពីរឿងដែលពូទៅរៀននៅស្រុកចិនៗ កាលហ្នុងមូលហេតុអីបានគេឲ្យពូទៅរៀន?

នីៈ គេចង់ឲ្យទៅបំពេញវិជ្ជានៅស្រុកចិនៗ

រតនាៈ តើរៀនវិជ្ជាអីគេពូ?

នីៈ	រៀនអង់គ្លេសមិនដឹង រៀនបច្ចេកទេសយោធាមិនដឹង ខ្ញុំអត់ដឹងទេណា៎ ខ្ញុំមិនអាចដឹងទេ ព្រោះអ្នកដែលគេទៅមុនៗ អ្នកខ្លះគេទៅខាងយន្តហោះ រថក្រោះ កាំភ្លើងធំអីចឹងទៅ ។

វតនាៈ ចុះតើអ្នកដែលគេឲ្យទៅរៀនហ្នឹង ដូចពូអីអីចឹង តើមានលក្ខណៈពិសេសយ៉ាងម៉េចបានជាគេបញ្ជូនឲ្យទៅរៀនហ្នឹង?

នីៈ	ម៉េច?

វតនាៈ ដូចថាការបញ្ជូនទៅរៀនហ្នឹង ទាល់តែគេជ្រើសរើសដែរឬមួយក៏យ៉ាងម៉េច?

នីៈ	ជ្រើសរើស ។

វតនាៈ ពូរៀនពូកែជាងគេ ឬមួយក៏យ៉ាងម៉េចបានគេបញ្ជូនពូទៅហ្នឹង?

នីៈ	ទេ! ល្មមៗឲ្យតែទៅបាន ទៅហើយកាលហ្នុង មិនបាច់ជ្រើសរើសថាពូកែឬមិនពូកែ ឲ្យតែកូនកម្មាភិបាល ។

វតនាៈ អ៎! អីចឹងមុនពូទៅហ្នឹង មានអ្នកទៅមុនច្រើនដែរ?

នីៈ	គេទៅច្រើនដែរ ។

វតនាៈ ហើយអ្នកដែលទៅហ្នឹង តើមានត្រឡប់មកវិញឬនៅ?

នីៈ	ខ្លះត្រឡប់មកវិញ ខ្លះទាល់តែសម័យយើងវៀតណាមចូលហើយហ្នឹង បានត្រឡប់មកវិញ ។

វតនាៈ ពូដឹងថា ការឲ្យទៅហ្នឹង តើមានបញ្ជាមកពីខាងណាដែរ?

នីៈ	បញ្ជាមកពីខាងអគ្គមគ្គុទេសគេហ្នឹង ខាងតា ប៉ុល ពត ហ្នឹងហើយ ។ អ្នកដែលជ្រើសរើសទៅរៀនប្រហែលជាតា អៀង សារី តាមមើល ។ គាត់អ្នកខាងបណ្តុះបណ្តាលក្មេងណា៎ ខាងរៀនភាសាបរទេស ។

វតនាៈ កាលហ្នុង ពូបានស្គាល់ អៀង សារី ឬនៅ?

នីៈ	ស្គាល់ហើយ ។

វតនាៈ ម៉េចបានពូបានស្គាល់គាត់ កាលហ្នុង?

នីៈ	ស្គាល់ដោយសារគាត់ធ្លាប់យកខ្ញុំទៅលេង ។

វតនាៈ កាលពេលដែលពូនៅរៀនហ្នឹងអ្ហេស?

នីៈ	បាទ! គាត់ធ្លាប់ទៅសំណេះសំណាលជាមួយកុមារអីអីចឹងណា៎ ហើយក្រុមគ្រួសារខ្ញុំហ្នឹងបានទៅលេងជាមួយគាត់អីអីចឹង ។

វតនាៈ អ៎! អីចឹងពេលដែលពូនៅរៀនហ្នឹង ពូធ្លាប់បានចេញមកខាងក្រៅដែរ?

នីៈ	បាទ! ទៅលេងនៅកន្លែងគាត់រៀន ។

វតនាៈ កាលហ្នុងគាត់នៅឯណាពូ?

នីៈ	គេហៅមន្ទីរអីទេ ខ្ញុំភ្លេចបាត់អស់ហើយ ។

សុរិយ៉ាៈ ប១ ក្រសួងការបរទេសអ្អេស?

នីៈ នឹងហើយ ប១ហ្នឹងហើយ កន្លែងខ្ញុំថាផ្ទះកោងម៉ិញហ្នឹង ។

សុរិយ៉ាៈ អ៊ីចឹងកន្លែងគណរដ្ឋមន្ត្រីឥឡូវហ្នឹងអ្អេស?

នីៈ នឹងហើយ ។

សុរិយ៉ាៈ ផ្លូវទៅវាលវង់កប៉ាល់ហោះណ៎ា?

នីៈ បាទ! អាហ្នឹងគេហៅថា ប១ ហើយនឹង ។

សុរិយ៉ាៈ អ៎! គេយកអាហ្នឹងធ្វើជាក្រសួងការបរទេសតែម្តង?

នីៈ បាទ! នឹងហើយ ។

សុរិយ៉ាៈ ចុះអាបឹងត្របែកគេហៅអី?

នីៈ បឹងត្របែកហ្នឹង កន្លែងសាលារៀនកុមារហ្នឹង កាលហ្នុងមិនទាន់មានឈ្មោះអីត្រឹមត្រូវទេ ។

សុរិយ៉ាៈ កន្លែងប១ហ្នឹង អៀង សារី ធំជាងគេតែម្តង?

នីៈ បាទ!

រតនាៈ ចុះបន្ទាប់មក?

នីៈ បន្ទាប់មក ខ្ញុំចាំមិនបានទេ ។ ខ្ញុំស្គាល់តែប្រធានមន្ទីរ ពូរិន នោះ គាត់អ្នកគ្រប់គ្រងខាងមន្ទីរកុមារតែម្តង ។ អ្នករៀនភាសានៅលើគាត់ទាំងអស់ ។

សុរិយ៉ាៈ អ៎! រៀនភាសា គេទុកនៅក្រោមក្រសួងការបរទេសណ៎ា?

នីៈ បាទ!

រតនាៈ ហើយពេលរៀន រៀននៅកន្លែងហ្នឹងដែរ?

នីៈ រៀននៅហ្នឹងដែរ ។ គេរើសទៅប្រហែលជាពីរវគ្គ កុមារដូចខ្ញុំហ្នឹងណ៎ា អ្នកដែលមានវ័យចំណាស់ជាងខ្ញុំបន្តិច ហើយថ្នាក់ខ្ពស់ជាងបន្តិច ។

រតនាៈ កាលហ្នុងកុមារៗហ្នឹងមានអាយុពីប៉ុន្មានទៅប៉ុន្មានពូ បានគេដាក់ថាក្រុមកុមារហ្នឹង?

នីៈ ចាប់ពីអាយុ៧ឆ្នាំឡើង ទៅទល់នឹងអាយុម្ភៃឆ្នាំជាង ក្រោម៣០ឆ្នាំ ។

រតនាៈ ចុះអ្នកដែលបញ្ជូនទៅជាមួយពូ ដែលថាប្រុងបញ្ជូនទៅរៀនចិនហ្នឹង តើពូមានស្គាល់ឈ្មោះអ្នកណាខ្លះ ហើយជាកូនរបស់អ្នកណាដែរពូ?

នីៈ ស្គាល់មិនអស់ទេ ។

រតនាៈ តែមានចាំខ្លះៗទេពូ?

នីៈ ចាំបានតែ ឃីម មួយហើយស្អីទេមួយទៀត គេទប្រុស ភ្លេចបាត់ហើយ ឃីម ហ្នឹងស្រី ពួកហ្នឹងជិតដិតជាមួយខ្ញុំ អត់ស្គាល់ម៉ែឪគេទេ ។

រតនាៈ អ៎! ពូថា ក្រោយពេលឪពុកពូស្លាប់ទៅ គេអត់បញ្ជូនពូទៅទេ?

នី៖ អត់បានទៅទេ ។

វតនា៖ ចុះអ្នកផ្សេងៗទៀត ដែលគេប្រុសបញ្ជូនទៅហ្នឹង តើគេបញ្ជូនទៅឬអត់ពូ?

នី៖ បានទៅពីរនាក់ ។

វតនា៖ អ៊ីចឹង បើគេអត់មានបញ្ហាដូចពូអ៊ីចឹង គេឲ្យទៅ?

នី៖ បាទ!

វតនា៖ ចុះចំណែកពូ បន្ទាប់ពីឪពុកពូស្លាប់ទៅ គេឲ្យពូធ្វើអីទៅ?

នី៖ បន្ទាប់ពីឪពុកស្លាប់ទៅ នៅរៀនដដែល ។

វតនា៖ រៀនអន់គ្រូសដដែល?

នី៖ នឹងហើយ រហូតដល់វៀតណាមចូលណ៎ ។

វតនា៖ ៧៩?

នី៖ បាទ!

វតនា៖ ចុះពេលហ្នឹង តើ ប៉ុល ពត ដែលមកលេងពូ ឬក៏សួរនាំអីពីឪពុករបស់ពូទេ?

នី៖ គាត់អត់ដែលមកទេកាលហ្នុង មិនមែនតួនាទីរបស់គាត់ ។

សុរិយ៉ា៖ បងនិយាយអាពេល ប៉ុល ពត រត់នោះ វៀតណាមមកដល់ ប៉ុល ពត រត់យ៉ាងម៉េចទៅ ។
បងថារត់តាមទ្វារក្រោយអីនោះ?

នី៖ គាត់ចេញតាមផ្លូវសម្ងាត់របស់គាត់ ។

សុរិយ៉ា៖ អាក្រោយទន្លេបាសាក់ហ្នឹង?

នី៖ បាទ! អាហ្នឹងខ្ញុំអត់សូវដឹងដែរ ខ្ញុំអត់បាននៅណ៎ តាមពួបងប្អូនដែលនៅជាមួយគាត់និយាយ ។

វតនា៖ ចុះពូថា ពូទៅធ្វើការឲ្យ អៀង សារី នោះ តើពេលណាទៅពូ?

នី៖ នៅពេលដែលខ្ញុំចេញពីភ្នំពេញទៅ នៅពេលដែលខ្ញុំធំដឹងក្តី ពេញវ័យ អាយុ១៥ឆ្នាំ ។ គាត់
យកខ្ញុំទៅរៀនខាងវិទ្យុទាក់ទង ។

វតនា៖ អ៊ីចឹងពេលដែលពូរត់ចេញទៅហ្នឹង ពូរត់ទៅជាមួយគាត់ ឬក៏រត់ទៅជួបគ្នានៅទីនោះ?

នី៖ ទៅជួបគ្នានៅព្រំដែន ។

វតនា៖ កាលហ្នុងពូរត់ទៅដល់ណា បានជួបគាត់?

នី៖ ទៅដល់ស្វាយស៊ីសុផុន ។

វតនា៖ អ៊ីចឹងអ្នកដែលនៅកងកុមារហ្នឹង រត់ចេញទៅៗទាំងអស់?

នី៖ បែកបាក់គ្នាមួយចំនួន ។ នៅជុំគ្នាខ្លះ បែកខ្លះ ពេលដែលរទេះភ្លើងដាច់ណ៎ ។

វតនា៖ អ៎! ចេញទៅ ពូជិះរទេះភ្លើងទៅដល់ណាពូ?

នី៖ ទៅដល់ស្វាយស៊ីសុផុនតែម្តង ។

រតនាៈ ទៅដល់ហ្នឹង ពូទៅធ្វើការខាងវិទ្យុទាក់ទង?

នីៈ ទាល់តែទៅដល់ព្រំដែនថៃណ៎ា ឆ្នាំប៉ុន្មាន យូរដែរហ្នឹង ។ ឆ្នាំ៨២បាន១ចេញទៅធ្វើការ ។ ទៅបំពេញវិជ្ជារៀនសូត្រអក្សរខ្មែរថែមទៀត ។

រតនាៈ ចុះពូ ខ្ញុំចង់សួររឿង ប៉ុល ពត ណា៎ ។ ពូកាលហ្នុងហេតុអីបានជា ប៉ុល ពត និងប្រពន្ធរបស់គាត់អត់នៅជុំគ្នាអីចឹង?

នីៈ ខ្ញុំអត់ដឹងដែរ ។

រតនាៈ អត់ដឹងថាមានបញ្ហាអីទេ?

នីៈ អត់ដែលដឹងថាមានបញ្ហាអីទេ ប៉ុន្តែគាត់នៅផ្សេង ប្រពន្ធគាត់នៅផ្សេង ។

រតនាៈ ហើយអត់ដែលមកលេងទៀត?

នីៈ អត់ដែលសូវមកលេងទេ តែកូនក្មួយគាត់ទេ ទៅមក លេង ។

រតនាៈ ចុះពូដែលឮគាត់និយាយពីរឿងប្រពន្ធគាត់ឬអត់?

នីៈ អត់ដែលនិយាយផង ។

រតនាៈ ចុះពូ ប៉ុល ពត រៀបការពេលណា ពូមានដឹងទេ?

នីៈ អត់ដឹងទេ ។ គ្រាន់តែដឹងថា ប្រពន្ធគាត់ហ្នឹង ហើយនិងប្រពន្ធ អៀង សារី ហ្នឹងជាបងប្អូន ។

ពីវ៉នៈ ចុះប្រពន្ធគាត់ចំណាស់ណាពូ កាលហ្នុង?

នីៈ ចាស់ហើយ ស្គមហើយ ។

រតនាៈ ខ្ទង់អាយុប៉ុន្មានពូ កាលហ្នុង?

នីៈ អាយុហាជាង ហុបឬមិនដឹង ។

រតនាៈ តែអត់ទាន់មានកូនមានចៅទេ?

នីៈ អត់មានទេ ។

រតនាៈ ចុះកាលពូនៅជាមួយគាត់ហ្នឹង តើពូមានស្គាល់ អ្នកណាគេជាមិត្តភក្តិជិតដិតរបស់គាត់ជាងគេ?

នីៈ មិត្តភក្តិជិតដិត ខ្ញុំឃើញតែមន្ត្រី១គ្នាគាត់ហ្នឹងហើយ ដែលចូលជួប ក្រៅពីហ្នឹងគ្មានទេ ។

រតនាៈ អ្នកណាខ្លះពូ ដែលធ្លាប់ចូលលេងផ្ទះគាត់ ញ៉ាំបាយជាមួយគាត់ មើលទៅស្និតស្នាលជាងគេ?

នីៈ កាលហ្នុងដូចមិនសូវមានអ្នកចេញចូលប្រក្រតីទេ លើកលែងតែមានការណ៍ ។

រតនាៈ ចុះចំពោះឪពុកពូវិញ ពេលដែលពូដឹងក្តីឡើង គាត់ក្លាយទៅជាគណតំបន់១០៥ហើយអ្ហេស?

នីៈ បាទ!

រតនាៈ ចុះពូមានដឹងទេ ថាមុន១ហ្នឹង គាត់ធ្វើការអីខ្លះទៅ? គាត់ចេញតស៊ូតាំងពីឆ្នាំណា អីឆ្នាំណាទៅ?

នីៈ ខ្ញុំអត់ដឹងទេ រឿងតស៊ូ ចាស់១បានដឹង ដូចមីងអី គាត់អាចដឹងហើយ ។

រតនាៈ ចុះឆ្នាំណាបានពូត្រឡប់មកដល់ភូមិវិញពូ?

នីៈ មកដល់ភូមិនេះវិញ?

រតនាៈ ចា៎!

នីៈ ខ្ញុំមកឆ្នាំ៩៦ ។

រតនាៈ ម៉េចបានពូទើបតែមក?

នីៈ ខ្ញុំមក មើលកាលផ្ដាច់ខ្លួនហ្នឹង ខ្ញុំមកភូមិវិញ ។

រតនាៈ ចុះកាលពេលដែលចេញទៅក្លាមហ្នឹង ពូអត់ចង់ត្រឡប់មកនៅភូមិវិញទេ? ម៉េចបានពូទៅដល់ស្វាយស៊ីសូផុនហ្នឹង?

នីៈ ចង់ដែរ តែមិនដឹងផ្លូវមក ចេះតែទៅរហូតតាមគេទៅ ។ មកម្ដងដែរ តែមកទៅ មេបញ្ជាការខ្ញុំហ្នឹង គាត់ស្ទាក់យកវិញ កាលឆ្នាំ៧៩ហ្នឹងណា៎ នៅអូរគ្រាង នៅវត្តខ្មែមឥឡូវហ្នឹងណា៎ ។ ហើយអ៊ីចឹងគេប្រជុំប្រកាសថា ឥឡូវក្មួយៗកុមារទាំងអស់ហ្នឹង ឲ្យបំបែកគ្នាទៅស្រុករៀងខ្លួន ព្រោះថា អង្គការគេហ្នឹងចង់អស់សង្ឃឹមហើយណា៎ វាធ្លាក់ដីថៃ ។ ដល់អ៊ីចឹងមេបញ្ជាការខ្ញុំ គាត់ទៅទទួលយកមកវិញ កុមារប្រហែលជា៨នាក់ ពួកខ្ញុំ ។

រតនាៈ មេបញ្ជាការហ្នឹងឈ្មោះអីដែរពូ?

នីៈ ឈ្មោះ លោក សឿ ហុង ។

រតនាៈ អ៊ីចឹងពូមកធ្វើទាហានជាមួយគាត់វិញ?

នីៈ បាទ!

រតនាៈ បែកពី អៀង សារី?

នីៈ អត់បែកទេ មកនៅមន្ទីរជាមួយគាត់វិញ ។

សុរិយ៉ាៈហុង មន្ទីរប១ហ្នឹងតែម្ដង?

នីៈ នឹងហើយ ។

សុរិយ៉ាៈហុង ហ្នឹងប្រវត្តិអ្នកមកពីណាអីដែរ?

នីៈ ខ្ញុំអត់ដឹងដែរ ។

សុរិយ៉ាៈតែនៅមន្ទីរ ប១ តាំងពីយូរហើយ?

នីៈ បាទ!

សុរិយ៉ាៈនៅក្បែរ អៀង សារី តែម្ដង ។

នីៈ បាទ!

សុរិយ៉ាៈគាត់ធ្វើអីដែរ នៅក្បែរ អៀង សារី គាត់ជាអ្នកសរសេររបាយការណ៍ ឬក៏ជាអ្នកការពារ?

នីៈ អត់ដឹងទេបង ប្រហែលជាគាត់ហ្នឹង ថ្នាក់លើ ។ ធ្វើការធំជាង ពូរិន បន្តិចណា៎ តែគាត់មាន តួនាទីអី ខ្ញុំអត់ដឹងទេ ។

សុរិយ៉ាៈស្អី ហុង មុិញ?

នីៈ ស៊ូ ហុង ។

សុរិយ៉ាៈគាត់អ្នកស្រុកណាដែរ?

នីៈ គាត់អ្នកកំពង់ធំ ។

រតនាៈ ចុះពូនៅជាមួយ អៀង សារី អីចឹង ពូដឹងថាគាត់មានសកម្មភាពអីខ្លះ ទៅដល់កន្លែងណា៎ខ្លះ?

នីៈ ចំពោះខ្ញុំ ខ្ញុំដឹងថា គាត់គ្រប់គ្រងផ្នែកក្រសួងការបរទេស ។

រតនាៈ ចុះពេលដែលគាត់រត់ទៅព្រៃ?

នីៈ ពេលរត់ទៅព្រៃ គាត់អត់មានធ្វើទីតាំងអីផង ។ គាត់គ្រប់គ្រងខាងសេដ្ឋកិច្ច កាលហ្នុងខ្ញុំអត់ដឹងច្បាស់ដែរណា៎ ។

រតនាៈ កាលហ្នុងគាត់នៅស្វាយស៊ីសុផុនហ្នឹងតែម្តង?

នីៈ អាពេលរត់ទៅហ្នឹងអ្ហេស?

រតនាៈ ចា៎! ពេលដែលពូនៅជាមួយ អៀង សារី ធ្វើខាងវិទ្យុទាក់ទង ។

នីៈ ខ្ញុំទៅដល់ព្រំដែនហើយ នៅកន្លែងស្រុកម៉ាឡៃ កាលហ្នុងស្រុកម៉ាឡៃនៅព្រៃនៅឡើយទេ ព្រៃឫស្សីតែម្តង ។ ទៅនៅហ្នឹង គាត់បើកធ្វើសាលារៀនធ្វើអីសម្រាប់កុមារអីចឹងទៅណា៎ ។ ឲ្យគេធ្វើសាលារៀន គាត់យកចិត្តទុកដាក់ជាមួយក្មេងណាស់ គាត់ហ្នឹង រឿងការរៀនសូត្រហ្នឹង ។

រតនាៈ ពូរៀបការនៅឯណា?

នីៈ រៀបការនៅហ្នឹង ទើបតែយកបានមួយឆ្នាំ មានកូនមួយ ។

រតនាៈ ចុះពូ ថាស្គាល់ប្រពន្ធទីពីររបស់ ប៉ុល ពត?

នីៈ ស្គាល់ ខ្ញុំនៅហ្នុង ដូចថាការទាក់ទងទៅមកៗយើងដឹងណា៎ ។

រតនាៈ កាលហ្នុងគាត់ការឆ្នាំប៉ុន្មាន ជាមួយប្រពន្ធទីពីរហ្នឹង?

នីៈ ខ្ញុំចាំអត់បានទេ ប្រហែលជា៨០ជាង មិនដឹង៨០ប៉ុន្មានទេ ។

រតនាៈ អ៎! អីចឹងពេលដែលគាត់យកប្រពន្ធទីពីរហ្នឹង មិនមែនពេលដែលពូនៅជាមួយគាត់ហ្នឹងទេ?

នីៈ អត់ទេ គាត់យកពេលខ្ញុំបែកហើយ គាត់យកនៅសំឡូតណា៎ កាលគាត់មិនទាន់មកអន្លង់វែងណា៎ ។

រតនាៈ ចុះកាលហ្នុងគាត់ដាច់គ្នាជាមួយប្រពន្ធទីមួយគាត់ឬនៅ?

នីៈ ប្រពន្ធទីមួយគាត់នៅផ្សេងៗ នៅជាមួយប្រពន្ធអ៊ំ អៀង សារី នៅជាមួយម្តាយគាត់ ។

សុរិយ៉ាៈនៅអន្លង់វែងឥឡូវមានភូមិ១០៥អ្ហី?

នីៈ មាន ។

សុរិយ៉ាៈសុទ្ធតែខ្មែរខាងណោះអ្ហេស នៅរស់នៅហ្នុង?

នីៈ បាទ!

សុរិយ៉ាៈខ្មែរអ្នកសល់មក ធំៗ អ្ហេស?

នីៈ ចង់និយាយថាអ្នកមណ្ឌលគិរី ។

សុរិយ៉ាៈចង់ឲ្យបងរៀបរាប់អ្នកធំៗដែលនៅរស់ នៅភូមិអន្ទង់វែងហ្នឹងណា៎ នៅភូមិ១០៥ហ្នឹង តើមាន អ្នកណាខ្លះ ដែលនៅរស់?

នីៈ នៅរស់ឥឡូវហ្នឹងមាន ពូអន ស៊ី, តាសារ៉ុន, ឌិប, បងទឹម ។

សុរិយ៉ាៈឌិប ហ្នឹងពីណាគេ?

នីៈ ឌិប ហ្នឹងមេទ័ព ។ កាលលើកមុនគេហៅវរសេនាធំ កាលលើកមុនណា៎ កាលខ្ញុំនៅ ។

សុរិយ៉ាៈហើយស្អីទៀតម៉ិញ?

នីៈ ពូទឹម អីហ្នឹងមកធ្វើការនៅហ្នឹងដែរ, តាទេវិច ហ្នឹងមេឃុំឥឡូវហ្នឹង ។

សុរិយ៉ាៈចុះខ្ញុំឮល្បៀងៗថា តាឡាំ នោះធ្វើអី?

នីៈ ឡាន់ រស់នៅមណ្ឌលគិរីឥឡូវនេះ ។

សុរិយ៉ាៈស្អី ឡាំ ដែរ? តាឡាំ ហ្នឹងជាស្នងការប៉ូលីសនៅមណ្ឌលគិរីអ្ហី?

នីៈ ពីដើមនៅក្រចេះ ឥឡូវនៅមណ្ឌលគិរី ។

សុរិយ៉ាៈនៅដល់ឥឡូវហ្នឹង ។ ឡាំ ហ្នឹងហើយ ដែលនៅរស់ រត់ទៅជាមួយ ញ៉ុន ហ្នឹងអ្ហេស?

នីៈ ឡាំ នៅនេះ ។

សុរិយ៉ាៈឡាំ ហ្នឹង យើងអត់ទាន់បានសួរផង ។ ឡាំ នៅមណ្ឌលគិរីតែម្តង នៅសែនមនោរម្យតែម្តង?

នីៈ សែនមនោរម្យ ។

សុរិយ៉ាៈសួរគេទៅថាធ្វើប៉ូលីស គេស្គាល់ហើយឈ្មោះ ឡាំៗ ហ្នឹង ។

នីៈ គាត់ធ្វើអីឥឡូវហ្នឹងឈ្មោះ ឡាំ ហ្នឹង ។

តូយៈ គាត់មុននៅស្នងការខេត្តក្រចេះ ។

រតនាៈ ចុះ តាឡាន់ នៅរស់ដែរ?

នីៈ តាឡាន់ នៅល្បួនទឹក ។

សុរិយ៉ាៈល្បួនទឹក នៅឯណា?

នីៈ ឃុំនឹងដែរ ។ ផ្ទះនៅស្រែជ្រៃឥឡូវហ្នឹងនោះ ។

សុរិយ៉ាៈគាត់ជាអតីតខាងកងសន្តិសុខជាមួយ ឡេង?

នីៈ បាទ!

សុរិយ៉ាៈ ចុះ គាំ នោះ?

នីៈ គាំ ណា?

សុរិយ៉ាៈ គាំ ជាប្រធានគុកនោះ ក១១?

តូយៈ ក១១ នៅជាមួយ តា ឈិត ឈៀ ។

សុរិយ៉ាៈ តែក្រោមទេអ្ហី? ក្រោម តាឡាន់ តាឡេង ទេ?

នីៈ ក្រោម ។

តូយៈ អត់ទេ ដូចយើងធ្វើប៉ូលីសអ៊ីចឹង មានខាងសន្តិសុខ ខាងសណ្តាប់ធ្នាប់ ខាងចរាចរណ៍អីអ៊ីចឹង ណា៎ ។

នីៈ ពូសុភា ហ្នឹងទទួលខាងមន្ត្រីរាជការដែលមានទោស ។

សុរិយ៉ាៈ អ៊ំ! ការដែលមានទោស សុភា ទទួលខុសត្រូវតែម្តង?

នីៈ បាទ!

សុរិយ៉ាៈ អាហ្នឹងដូចប៉េអឹមអ៊ីចឹង?

នីៈ នឹងហើយ ។ តាឡេង និង តាឡាន់ ហ្នឹង ទាហានតែម្តង ។

សុរិយ៉ាៈ តែទាហានគាត់ជាអ្នកចាប់?

នីៈ តែទាហាន ប្រជាជនគាត់មានសិទ្ធិចាប់ ។

សុរិយ៉ាៈ អ៊ីចឹងបានន័យថា សន្តិសុខក៏ដូចជាប៉េអឹមដែរ?

នីៈ បាទ!

សុរិយ៉ាៈ ហើយបើតា សុភា វិញ ចាប់ខាងមន្ត្រីរាជការអាហ្នឹងគាត់តែម្តង?

នីៈ បាទ!

រតនាៈ អ៊ីចឹងពូខ្ញុំអរគុណពូច្រើនហើយដែលបានផ្តល់បទសម្ភាសន៍ឲ្យខ្ញុំ ។

នីៈ បាទ!ៗ